# គោលការណ៍ណែនាំ និងពីធីសារស្រាវជ្រាវជំងឺរបេង



ខែកញ្ញា ឆ្នា ឆ្នាំ២០២៣

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

USAID
FROM THE AMERICAN PEOPLE

TB DIAH
Tuberculosis Data, Impact Assessment and Communications Hub

# គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេង



ខែកញ្ញា ឆ្នា ឆ្នាំ២០២៣

This publication was produced with the support of the United States Agency for International Development (USAID) under the terms of the TB Data, Impact Assessment and Communications Hub (TB DIAH) Associate Award No. 7200AA18LA00007. TB DIAH is implemented by the University of North Carolina at Chapel Hill, in partnership with John Snow, Inc. Views expressed are not necessarily those of USAID or the United States government.
MS-23-218-KH TB

# បុព្វបទ

មហាសន្និបាតអង្គការសហប្រជាជាតិលើកដំបូង (UNGA) កិច្ចប្រជុំថ្នាក់ខ្ពស់ស្តីពីជំងឺរបេង (UNGA-HLM-TB) បាននាំឱ្យមានការអនុម័តសេចក្តីប្រកាសនយោបាយស្តីពីជំងឺរបេងកាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៨។ សេចក្តីថ្លែងការណ៍នេះបានអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការបញ្ចប់ការរីករាលដាលនៃជំងឺរបេងទូទាំងពិភពលោកនៅឆ្នាំ ២០៣០ និង រួមបញ្ចូលនូវគោលដៅប្រកបដោយមហិច្ឆតា និងជិតដល់សម្រាប់ការបង្កើនទំហំសេវាថែទាំ និងបង្ការជំងឺរបេង។ វាក៏រួមបញ្ចូលផងដែរនូវការប្តេជ្ញាចិត្តលើការស្រាវជ្រាវសម្រាប់ឧបករណ៍ថ្មី គោលការណ៍នៃសមធម៌ និងសិទ្ធិអ្នកជំងឺ និងតម្រូវការជំនួន។
កម្ពុជាប្តេជ្ញាក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅជាសាកលទាំងនេះ ហើយផែនការយុទ្ធសាស្ត្រជាតិដើម្បីបញ្ចប់ជំងឺរបេងនៅកម្ពុជាឆ្នាំ ២០២១-២០៣០(NSP) បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តនេះដោយទទួលបានពីអនុសាសន៍របស់អង្គការសហប្រជាជាតិ។

ផែនការយុទ្ធសាស្ត្រជាតិនេះ ផ្តោតលើតម្រូវការសម្រាប់ការសម្រេចបាននូវគោលដៅជាតិបញ្ចប់ជំងឺរបេង ហើយត្រូវបានដឹកនាំដោយយុទ្ធសាស្ត្រ "ស្វែងរក-ព្យាបាល-ការពារ-កសាង ពង្រឹង និងទ្រទ្រង់" ដោយសង្កត់ធ្ងន់លើការដោះស្រាយអាទិភាពកម្មវិធី និងតម្រូវការជាក់លាក់។ ការផ្តោតសំខាន់គឺលើការធ្វើរោគវិនិច្ឆ័យដំបូងនៃអ្នកជំងឺរបេង (TB) ទាំងអស់ដោយប្រើប្រាស់ឧបករណ៍វិនិច្ឆ័យដែលមានលក្ខណៈរសើបជាងមុន កាត់បន្ថយការចម្លង និងព្យាបាលអ្នកដែលទាក់ទងដំបូងជាមួយនឹងថ្នាំ របប និងប្រព័ន្ធគាំទ្រអ្នកជំងឺដែលមានប្រសិទ្ធភាពបំផុត។ វាត្រូវបានបំពេញបន្ថែមដោយការគ្រប់គ្រងការឆ្លងមេរោគ និងការគ្រប់គ្រងការឆ្លងមេរោគរបេងសម្ងំនៅក្នុងប្រជាជនដែលមានហានិភ័យ។ ទាំងអស់នេះត្រូវបានគាំទ្រដោយការបង្កើតបរិយាកាសអំណោយផលជាមួយនឹងមូលនិធិ និងធនធានគ្រប់គ្រាន់ ក៏ដូចជាប្រព័ន្ធតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ និងការស្រាវជ្រាវតាមកម្មវិធីដ៏រឹងមាំ។

អវត្តមាននៃគោលការណ៍ណែនាំស្រាវជ្រាវជំងឺរបេងនៅកម្ពុជា ទាមទារឱ្យមានការបង្កើតគោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេង ក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) ដើម្បីធានាបាននូវសុពលភាពផ្នែកវិទ្យាសាស្ត្រ និងសីលធម៌នៃការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា។ គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងក៏បានរួមបញ្ចូលផងដែរនូវរបៀបវារៈស្រាវជ្រាវជំងឺរបេងដែលត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការកម្ពុជាសម្រាប់ការស្រាវជ្រាវជំងឺរបេង (CCTBR)។

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន  ទទួលស្គាល់ការរួមចំណែករបស់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសដៃគូរយៈពេលវែងនៃកម្មវិធីជាតិជំងឺរបេង៖ គម្រោងទិន្នន័យជំងឺរបេង ការវាយតម្លៃផលប៉ះពាល់ និងមជ្ឈមណ្ឌលទំនាក់ទំនង (TB DIAH) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) វិទ្យាស្ថានជាតិសុខភាពសាធារណៈ សមាជិកគណៈកម្មាធិការកម្ពុជាសម្រាប់ការស្រាវជ្រាវជំងឺរបេង (CCTBR) និងអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូរកម្មវិធីជាតិ ។ យុទ្ធសាស្ត្រពហុវិស័យ និងកិច្ចសហការនេះធានាថា គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងឆ្លុះបញ្ចាំងពីការគិតរួមដ៏ល្អបំផុតរបស់អ្នកពាក់ព័ន្ធជាច្រើនប្រភេទ។

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន  សូមថ្លែងអំណរគុណចំពោះ USAID តាមរយៈ TB DIAH សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលសម្របសម្រួលសម្រាប់ការអភិវឌ្ឍន៍ និងការបោះពុម្ពគោលការណ៍ណែនាំស្រាវជ្រាវទាំងនេះ។

ភ្នំពេញ ...ទី២៩..... ខែកញ្ញា ឆ្នាំ ២០២៣
ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងនេះត្រូវបានបង្កើតឡើងដោយមណ្ឌលទំនាក់ទំនងវាយតម្លៃផលប៉ះពាល់ និងទិន្នន័យជំងឺរបេង (TB DIAH) ដោយសហការជាមួយមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) គម្រោងគាំទ្រធនធានបច្ចេកទេស និងវិភាគ (STAR) វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) និងសមាជិកនៃគណៈកម្មាធិការសម្រាប់ការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា (CCTBR) នៅកម្ពុជា។ យើងសូមថ្លែងអំណរគុណចំពោះលោកវេជ្ជបណ្ឌិត ហួត ចាន់យុដា ប្រធានកមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន និងលោកវេជ្ជបណ្ឌិត សុង ង៉ាក់ អ្នកឯកទេសគ្រប់គ្រងជំងឺរបេងនៃបេសកកម្ម USAID ប្រចាំប្រទេសកម្ពុជា ចំពោះការគាំទ្ររបស់ពួកគាត់នៅក្នុងឯកសារស្រាវជ្រាវនេះ។

សូមអរគុណជាពិសេសចំពោះបុគ្គលខាងក្រោមសម្រាប់ការរួមចំណែករបស់ពួកគាត់៖

**Author**: Kai-Lih Liu, Ph.D., MPH, TB Research Capacity Building Advisor, TB DIAH Cambodia Team

**Reviewers**: Dr. An Yom, USAID STAR Advisor

Dr. Khun Kim Eam, Deputy Director, CENAT

Dr. Heng Sopheab, Deputy Director, National Institute of Public Health (NIPH)

Dr. Song Ngak, TB Management Specialist, USAID Cambodia Mission

Chean Mean, Team Leader, TB DIAH Cambodia Team

Knowledge Management (KM), TB DIAH

**Khmer Translation**: Dr. Khun Kim Eam, Deputy Director, CENAT

**Khmer Review**: Sohpa Chum, TB DIAH Cambodia Team

Sarady Sao, TB DIAH Cambodia Team

Him Phannary, TB DIAH Cambodia Team

# មាតិការ


បុព្វបទ ........ 3

សេចក្តីថ្លៃងអំណរគុណ ........ 4

មាតិការ ........ 5

អក្សរកាត់ ........ 8

1. សេចក្តីផ្តើម ........ 10

2. គណៈកម្មាធិការសម្រាប់ការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា (CCTBR) ........ 13

3. របៀបវារៈស្រាវជ្រាវជំងឺរបេង ........ 14

4. ការបង្កើតពិធីសារស្រាវជ្រាវ ........ 21

4.1. ចំណងជើងគម្រោង ........ 21

4.2. បញ្ជីអ្នកសិក្សាស្រាវជ្រាវ ........ 21

4.3. សេចក្តីសង្ខេបអំពីការស្រាវជ្រាវ ........ 22

4.4. សាវតារ/សេចក្តីផ្តើម ........ 22

4.5. គោលបំណងនៃការស្រាវជ្រាវ ........ 23

4.6. វិធីសាស្ត្រ ........ 24

4.6.1. វិធីសាស្ត្របរិមាណវិស័យ ........ 24

4.6.2. វិធីសាស្ត្រគុណវិស័យ ........ 30

4.6.3. វិធីសាស្ត្រចម្រុះ ........ 32

4.7. វិធីសាស្ត្រជ្រើសរើសសំណាកស្រាវជ្រាវ ........ 33

4.7.1. វិធីសាស្ត្រជ្រើសរើសសំណាកប្រូបាប៊ីលីតេ ........ 33

4.7.2. វិធីសាស្ត្រជ្រើសរើសសំណាកមិនមែនប្រូបាប៊ីលីតេ ........ 35

4.8. ឧបករណ៍ប្រមូលទិន្នន័យ ........ 36

4.8.1. ឧបករណ៍ប្រមូលទិន្នន័យបរិមាណវិស័យ ........ 36

4.8.2. ឧបករណ៍ប្រមូលទិន្នន័យគុណវិស័យ ........ 37

4.9. ផែនការប្រមូលទិន្នន័យ ........ 38

4.10. ផែនការគ្រប់គ្រងទិន្នន័យ ........ 39

4.11. ផែនការវិភាគទិន្នន័យ ........ 40

4.11.1. ផែនការវិភាគទិន្នន័យបរិមាណវិស័យ ........ 40

4.11.2. ផែនការវិភាគទិន្នន័យគុណវិស័យ ........................................................................................40
4.12. លទ្ធផលរំពឹងទុក ..................................................................................................................41
4.13. ក្រុមសីលធម៌ស្រាវជ្រាវ ..........................................................................................................41
4.14. ឯកសារយោង ......................................................................................................................41
4.15. ឧបសម្ព័ន្ធ ...........................................................................................................................43
5. ក្រុមសីលធម៌ស្រាវជ្រាវ និងការពិនិត្យឡើងវិញ.................................................................................44
5.1. សារៈសំខាន់នៃក្រុមសីលធម៌ស្រាវជ្រាវ.........................................................................................44
5.2. ការការពារបុគ្គលគោលដៅជាមនុស្ស .........................................................................................44
5.3. ការរក្សាការសម្ងាត់ ..............................................................................................................45
5.4. ការយល់ព្រម និងសំណង .......................................................................................................46
5.5. តម្លាភាព និងគណនេយ្យភាព....................................................................................................47
5.6. ការលួចចម្លង និងកម្មសិទ្ធិបញ្ញា ..............................................................................................48
5.7. វិធានការការពារផ្នែកក្រុមសីលធម៌ស្រាវជ្រាវ..................................................................................48
5.8. ការពិនិត្យរបស់គណៈកម្មការជាតិស្រាវជ្រាវសុខភាព.........................................................................48
6. ការគ្រប់គ្រងទិន្នន័យស្រាវជ្រាវ.......................................................................................................51
6.1. កម្មសិទ្ធិទិន្នន័យ ..................................................................................................................51
6.2. ការប្រមូលទិន្នន័យ និងការរក្សាទុក ............................................................................................52
6.3. ការការពារ និងរក្សាទុកទិន្នន័យ................................................................................................52
6.4. ការចែករំលែកទិន្នន័យ...........................................................................................................53
7. ការវិភាគនិន្នន័យស្រាវជ្រាវ ........................................................................................................ 55
7.1. ការវិភាគទិន្នន័យបរិមាណវិស័យ............................................................................................. 55
7.1.1. លក្ខខណ្ឌតម្រូវក្នុងការវិភាគស្ថិតិ .................................................................................... 55
7.1.2. ទិន្នន័យបាត់បង់..............................................................................................................56
7.1.3. ការសិក្សាបែបសង្កេត .......................................................................................................56
7.1.4. ការធ្វើម៉ូដែលតិតថយក្រោយ ( Regression Modeling )...........................................................58
7.1.5. ទិន្នន័យចាប់ពីពេលវេលាដល់ព្រឹត្តិការណ៍ ឬការវិភាគពេលចាប់ផ្តើមដល់ចប់ ( Time-to-Event Data or Survival Analyses )..................................................................................................58
7.1.6. ការសាកល្បងគ្លីនីក............................................................................................................59
7.2. ការវិភាគទិន្នន័យគុណវិស័យ ...................................................................................................61

7.2.1. ការចម្លងទិន្នន័យ ....................................................................................................................61
7.2.2. ការសរសេរកូដទិន្នន័យ.......................................................................................................62
7.2.3. ការវិភាគទិន្នន័យ...............................................................................................................62
7.2.4. ការបកស្រាយទិន្នន័យ.........................................................................................................64
7.2.5. ការសម្រង់ និងការពណ៌នាក្រាស់ (Quotations and Thick Description)..........................64
7.3. ដែនកំណត់ .............................................................................................................................65
8. ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយការស្រាវជ្រាវ.....................................................................66
8.1. ភាពជាអ្នកនិពន្ធ.......................................................................................................................66
8.2. ប្រភេទនៃអត្ថបទស្រាវជ្រាវ..........................................................................................................66
8.2.1. ការស៊ើបអង្កេតដើម ..........................................................................................................66
8.2.2. ការសាកល្បងគ្លីនីក ..........................................................................................................67
8.2.3. របាយការណ៍សង្ខេប ..........................................................................................................67
8.2.4. លិខិតស្រាវជ្រាវ ...............................................................................................................68
8.2.5. លិខិតចំពោះអ្នកកែសម្រួល ..................................................................................................68
8.3. ជាតុផ្សំនៃឯកសារស្រាវជ្រាវមិនទាន់បោះពុម្ព...................................................................................69
8.4. ការពិនិត្យឯកសារស្រាវជ្រាវមិនទាន់បោះពុម្ព...................................................................................71
8.4.1. ការពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត (Peer Review)..........................................................71
8.4.2. ការពិនិត្យឡើងវិញក្រោយពីការពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត............................................73
9. ការសន្និដ្ឋាន .............................................................................................................................75
ឯកសារយោង.................................................................................................................................76
ឧបសម្ព័ន្ធ .....................................................................................................................................78

# អក្សរកាត់

| | |
|---|---|
| APA | American Psychological Association |
| CCTBR | Cambodia Committee for TB Research |
| CENAT | National Center for Tuberculosis and Leprosy Control |
| CHAI | Clinton Health Access Initiative |
| COMMIT | Community Mobilization Initiatives to End Tuberculosis |
| FGD | focus group discussion |
| GF | The Global Fund to Fight Aids, Tuberculosis and Malaria |
| HR | hazard ratio |
| IDI | in-depth interview |
| IPC | Institute Pasteur of Cambodia |
| KHANA | Khmer HIV/AIDS NGO Alliance |
| LHSS | Local Health System Sustainability ( Project ) |
| MOH | Ministry of Health |
| NCHADS | National Center for HIV/AIDS, Dermatology, and STD |
| NECHR | National Ethics Committee for Health Research |
| NIPH | National Institute of Public Health |
| NSSF | National Social Security Fund |
| NTP | National Tuberculosis Program ( Cambodia ) |
| NUS | National University of Singapore |
| OI | opportunistic infection |
| PH | proportional hazards |
| PI | principal investigator |
| PLHIV | People Living with HIV |
| PPM | public-private mixed |
| SAP | statistical analysis plan |

| | |
|---|---|
| SDG | Sustainable Development Goals |
| STAR | Sustaining Technical and Analytical Resources |
| TB | tuberculosis |
| TB DIAH | Tuberculosis Data, Impact Assessment and Communication Hub |
| TPT | tuberculosis preventive treatment |
| USAID | United States Agency for International Development |
| WHO | World Health Organization |

# 1. សេចក្តីផ្តើម

ប្រទេសកម្ពុជាបានចាកចេញពីបញ្ជីប្រទេសចំនួន ៣០ ដែលមានបន្ទុកជំងឺរបេងធ្ងន់ជាងគេលើពិភពលោក ប៉ុន្តែនៅតែបន្តស្ថិតក្នុងបញ្ជីតាមដានជំងឺរបេងសកលនៅឡើយ។ ដោយផ្អែកលើរបាយការណ៍ជំងឺរបេងសកលឆ្នាំ ២០២១ របស់អង្គការសុខភាពពិភពលោក អាំងស៊ីដង់ជំងឺរបេងគឺ ២៧៤ នាក់ក្នុងចំណោមមនុស្ស ១00,000 នាក់ ទន្ទឹមនឹងនោះ អត្រាមរណភាពគឺ ២០ នាក់ក្នុងចំណោមមនុស្ស ១00,000 នាក់ក្នុងឆ្នាំ២០២០។ អត្រាជោគជ័យនៃការព្យាបាលជំងឺរបេងត្រូវបានរក្សាបានជាង ៩0% ក្នុងអំឡុងរយៈពេល ២៣ ឆ្នាំចុងក្រោយមកនេះ។ កម្មវិធីជាតិកំចាត់រោគរបេងនៅកម្ពុជា សម្រេចបានអត្រាជោគជ័យ ៩៥,៦% ក្នុងឆ្នាំ ២០២១ ដែលលើសពីគោលដៅជាតិ ៩0%។ របាយការណ៍ក៏បានបង្ហាញផងដែរថា ក្នុងឆ្នាំ ២០២១ អ្នកជំងឺរបេងចំនួន ៤៩៣ នាក់បានស្លាប់ (១,៨%) ក្នុងអំឡុងពេលព្យាបាល អ្នកជំងឺ ៥២ នាក់ (0,២%) បានបរាជ័យ ហើយអ្នកជំងឺ ៤៣៣ នាក់ (១,៦%) បានបោះបង់ការព្យាបាល។

ក្នុងឆ្នាំ ២០១៩ ការពិនិត្យវាយតម្លៃកម្មវិធីរួមគ្នា (JPR) បានទទួលស្គាល់ថា កម្ពុជាកំពុងដើរលើផ្លូវត្រូវដើម្បីបំពេញតាមការប្តេជ្ញាចិត្តជាតិឆ្ពោះទៅសម្រេចបានយុទ្ធសាស្ត្របញ្ចប់ជំងឺរបេង (End TB), គោលដៅទាក់ទងនឹងជំងឺរបេងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និងសកម្មភាពដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់ដំបូងរបស់អង្គការសហប្រជាជាតិ (UNLHM) ស្តីពីជំងឺរបេង។ កម្មវិធីជាតិកំចាត់រោគរបេងរបស់ក្រសួងសុខាភិបាលសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ឆ្នាំ១៩៩០-២០១៥ ក្នុងការបញ្ច្រាស់អាំងស៊ីដង់ និងកាត់បន្ថយអត្រាប្រេវ៉ាឡង់ និងការស្លាប់ដោយសារជំងឺរបេងចំនួន ៥0% ចាប់តាំងពីឆ្នាំ ២០១១ ដែលមានរយៈពេល ៤ ឆ្នាំមុនពេលកំណត់។ ថ្មីៗនេះ កម្មវិធីជាតិកំចាត់រោគរបេង ក៏បានឈានដល់គោលដៅសំខាន់ឆ្នាំ ២០២០ ក្នុងការកាត់បន្ថយអត្រាអាំងស៊ីដង់ជំងឺរបេងមកត្រឹម ២0%។

សម្រាប់ UNLHM គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងយុទ្ធសាស្ត្របញ្ចប់ជំងឺរបេងសម្រាប់ប្រទេសកម្ពុជា ដែលជាវិធីសាស្ត្រ "ស្វែងរក ព្យាបាល-បង្ការ-កសាង ពង្រឹង និងរក្សានិរន្តរភាព" ត្រូវបានអនុវត្តដោយផ្តោតជាពិសេសលើការដោះស្រាយអាទិភាពកម្មវិធី និងតម្រូវការជាក់លាក់។ យុទ្ធសាស្ត្រព្យាបាល និងបង្ការជំងឺរបេងទាំងអស់ ត្រូវបានគាំទ្រដោយបរិយាកាសអំណោយផលដោយមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ក៏ដូចជាប្រព័ន្ធឃ្លាំមើល (surveillance) តាមកម្មវិធីដ៏រឹងមាំមួយ ការតាមដាន និងវាយតម្លៃ (M&E) និងសកម្មភាពស្រាវជ្រាវផ្សេងទៀត។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីសម្រេចបាននូវគោលដៅកំចាត់ជំងឺរបេងដ៏មានមហិច្ឆតាទាំងនេះ ចាំបាច់ត្រូវមានបច្ចេកវិទ្យាបដិវត្តន៍ថ្មី រួមទាំងការធ្វើរោគវិនិច្ឆ័យរហ័ស សាមញ្ញ នៅនឹងកន្លែងដើម្បីរកមើលការឆ្លងរោគរបេងសង្ងំ និងជំងឺរបេង របមន្តព្យាបាលរយៈពេលខ្លីសម្រាប់របេងសង្ងំ និងជំងឺរបេង ហើយទីបំផុតវ៉ាក់សាំងដ៏មានប្រសិទ្ធភាព គឺត្រូវការជាចាំបាច់។

ទាំងនេះតម្រូវឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការស្រាវជ្រាវ រួមជាមួយនឹងការបន្តដែលភ្ជាប់ទៅនឹងការស្រាវជ្រាវជាមូលដ្ឋានទៅនឹងរបបគំហើយ និងការអភិវឌ្ឍឧបករណ៍ថ្មីៗ និងជាចុងក្រោយបំផុត ភ្ជាប់ទៅនឹងការស្រាវជ្រាវបែបអនុវត្ត និងប្រតិបត្តិ ដែលអនុញ្ញាតឱ្យមានវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ដើម្បីសម្របទៅនឹងតម្រូវការជាក់លាក់របស់ប្រទេស។

ក្រៅពី សសរស្តម្ភទី១ "ការរួមបញ្ចូលការបង្ការ និងការថែទាំជំងឺរបេងដែលផ្តោតលើអ្នកជំងឺជាសំខាន់" និងសសរស្តម្ភទី២ "ការពង្រឹងគោលនយោបាយ និងប្រព័ន្ធគាំទ្រ" នោះ "ការស្រាវជ្រាវ និងការបង្កើតថ្មីកម្រិតខ្ពស់" ត្រូវបានចុះបញ្ជីជា សសរស្តម្ភទី៣ នៅក្នុង "យុទ្ធសាស្ត្របញ្ចប់ជំងឺរបេង" ដោយអង្គការសុខភាពពិភពលោក។ នៅក្នុងប្រទេសកម្ពុជា ជំងឺរបេងត្រូវ បានបញ្ចូលជាសសរស្តម្ភយុទ្ធសាស្ត្រមួយក្នុងចំណោមសសរស្តម្ភទាំងប្រាំនៅក្នុងផែនការយុទ្ធសាស្ត្រជាតិរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ដើម្បីបញ្ចប់ជំងឺរបេងឆ្នាំ ២០២១-២០៣០។ ដូច្នេះ ការស្រាវជ្រាវ និងការបង្កើតថ្មីៗស្តីពីជំងឺរបេងបានក្លាយជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់មួយក្នុងការបញ្ចប់ជំងឺរបេងនៅក្នុងប្រទេសកម្ពុជា។

អង្គការសុខភាពពិភពលោក បានកំណត់ឃើញបញ្ហាស្រាវជ្រាវជំងឺរបេងជាច្រើន ដែលបញ្ហាប្រឈមសម្រាប់ការបង្កើតគោលការណែនាំអំពីគោលនយោបាយជំងឺរបេងនៅទូទាំងពិភពលោក។ បញ្ហាប្រឈមទាំងនេះត្រូវបានកំណត់ដូចខាងក្រោម៖ កង្វះភស្តុតាងដែលមានគុណភាពល្អ ទិន្នន័យដែលមិនអាចចូលប្រើប្រាស់បានស្តីពីបទពិសោធន៍កម្មវិធីនៃអត្ថប្រយោជន៍ និងសុវត្ថិភាពកិច្ចអន្តរាគមន៍ និងភស្តុតាងមិនគ្រប់គ្រាន់ស្តីពីការទទួលយក លទ្ធភាពដែលអាចធ្វើបាន និងការចែកចាយធនធានប្រកបដោយសមធម៌ និងសុខភាព។

កម្មវិធីជាតិកំចាត់រោគរបេងកម្ពុជា បានប្តេជ្ញាពង្រឹងការស្រាវជ្រាវជំងឺរបេងក្នុងប្រទេសតាមរយៈវិធីសាស្ត្រផ្សេងៗគ្នា ដូចជា ការសម្របតាមទិសដៅសកលរបស់អង្គការសុខភាពពិភពលោកក្នុងការបញ្ចប់ជំងឺរបេងនៅឆ្នាំ ២០៣៥ តាមរយៈ "ការស្រាវជ្រាវ និងការបង្កើតថ្មីកម្រិតខ្ពស់" ជាមួយនឹងផែនការយុទ្ធសាស្ត្រជាតិដើម្បីបញ្ចប់ជំងឺរបេងនៅកម្ពុជាឆ្នាំ ២០២១-២០៣០ ដោយការពង្រឹង "ការឃ្លាំមើល(surveillance) ការត្រួតពិនិត្យ ការវាយតម្លៃ និងការស្រាវជ្រាវ" ហើយថែមទាំងផ្សារភ្ជាប់ជាមួយពីកម្មវិធីការពិនិត្យវាយតម្លៃរួមគ្នា (JPR) ក្នុងឆ្នាំ ២០១៩ ដើម្បី "បន្តតាមរកការច្នៃប្រឌិត និងការស្រាវជ្រាវ"។

ជាទូទៅ គោលការណ៍ណែនាំគឺជាឯកសារមួយប្រភេទដែលមានការណែនាំអំពីបញ្ហាសុខភាព រួមមានការណែនាំបែបគ្លីនិក អំពីសុខភាពសាធារណៈ ឬអំពីគោលនយោបាយ។ ដូចដែល WHO ស្នើឡើង គោលការណ៍ណែនាំទាំងនេះគួរតែត្រូវបានរៀបចំបន្ទាប់ពីការពិគ្រោះយោបល់អំពីវិសាលភាពនៃគោលការណ៍ណែនាំ និងបញ្ហាដែលត្រូវរាប់បញ្ចូល។ បច្ចុប្បន្ននេះ មិនមានគោលការណ៍ណែនាំអំពីការស្រាវជ្រាវជំងឺរបេងនៅក្នុងប្រទេសកម្ពុជាទេ។ ដូច្នេះ ចាំបាច់ត្រូវអភិវឌ្ឍគោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេង ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិ

កំចាត់រោគរបេង និងហង់សិនសម្រាប់ភាពត្រឹមត្រូវបែបវិទ្យាសាស្ត្រ និងក្រមសីលធម៌នៃសកម្មភាពស្រាវជ្រាវជំងឺរបេងនៅកម្ពុជា។ របៀបវារៈស្រាវជ្រាវដែលបង្កើតឡើងដោយ CCTBR ក្នុងឆ្នាំ២០២១ ក៏ត្រូវបានបញ្ចូលក្នុងគោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងនេះផងដែរ។

គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងរួមមានធាតុផ្សំដូចខាងក្រោម៖ (១) គណៈកម្មាធិការសម្រាប់ការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា (CCTBR) (២) របៀបវារៈស្រាវជ្រាវជំងឺរបេង (៣) ការអភិវឌ្ឍសំណើសិក្សាស្រាវជ្រាវ (៤) ការត្រួតពិនិត្យ និងក្រមសីលធម៌ស្រាវជ្រាវ (៥) ការគ្រប់គ្រងទិន្នន័យស្រាវជ្រាវ (៦) ការវិភាគទិន្នន័យស្រាវជ្រាវ និង (៧) ការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយការស្រាវជ្រាវ។ គោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងនេះនឹងត្រូវបានពិនិត្យ និងអនុម័តដោយសមាជិក CCTBR និងគួរតែត្រូវបានគាំទ្រដោយមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន និងក្រសួងសុខាភិបាល។ ភាគីពាក់ព័ន្ធការស្រាវជ្រាវនឹងជួយដល់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ដើម្បីពិនិត្យ និងអនុវត្តគោលការណ៍ណែនាំស្រាវជ្រាវជំងឺរបេងជាប្រចាំ។

គោលបំណងនៃគោលការណ៍ណែនាំ និងពិធីសារស្រាវជ្រាវជំងឺរបេងនេះ គឺ៖

(១) ធានានូវភាពត្រឹមត្រូវនៃការស្រាវជ្រាវជំងឺរបេង

(២) ផ្តល់នីតិវិធី និងបែបបទស្តង់ដារសម្រាប់សកម្មភាពស្រាវជ្រាវជំងឺរបេង

(៣) បង្កើត និងធ្វើបច្ចុប្បន្នភាពរបៀបវារៈស្រាវជ្រាវជំងឺរបេង និង

(៤)ធ្វើឲ្យប្រសើរឡើងនូវគុណភាពការបោះពុម្ពផ្សាយនិងការផ្សព្វផ្សាយការស្រាវជ្រាវជំងឺរបេង។

## 2. គណៈកម្មាធិការសម្រាប់ការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា (CCTBR)

នៅឆ្នាំ ២០២០ គណៈកម្មាធិការសម្រាប់ការស្រាវជ្រាវជំងឺរបេងនៅកម្ពុជា (CCTBR) ត្រូវបានបង្កើតឡើង ដើម្បីគូសវាសផែនទីធនធានដែលមានសម្រាប់ការស្រាវជ្រាវ ក៏ដូចជាដើម្បីកំណត់ និងដោះស្រាយការស្រាវជ្រាវជំងឺរបេងក្នុងស្រុក ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងតាមកម្មវិធី ក្នុងការសម្រេចបាននូវយុទ្ធសាស្ត្របញ្ចប់ជំងឺរបេង។ គោលបំណងជាក់លាក់នៃ CCTBR គឺដើម្បីជួយដល់កម្មវិធីជាតិកំចាត់រោគរបេង ក្នុងសកម្មភាពដូចខាងក្រោម៖

១. បង្កើតវេទិកាសម្រាប់ការចែករំលែកចំណេះដឹង និងកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងស្រាវជ្រាវជំងឺរបេងនៅថ្នាក់ជាតិ។
២. ដើម្បីបង្កើតផែនការស្រាវជ្រាវជំងឺរបេងជាក់លាក់នៅក្នុងប្រទេសដោយផ្អែកលើលក្ខណៈនៃអេពីដេមីជំងឺរបេង និងសារពើភ័ណ្ឌនៃធនធាន និងសកម្មភាព។
៣. ត្រួតពិនិត្យការអនុវត្តផែនការស្រាវជ្រាវ។
៤. រៀបចំផែនការផ្តល់មូលនិធិដល់ការស្រាវជ្រាវជំងឺរបេង និងការកសាងសមត្ថភាព។
៥. តស៊ូមតិសម្រាប់ការស្រាវជ្រាវជំងឺរបេង និងការផ្តល់មូលនិធិ។

CCTBR ត្រូវបានដឹកនាំដោយប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) សហប្រធានដោយអនុប្រធាន CENAT និងតំណាង NIPH ដោយមានលេខាធិការដ្ឋានតំណាងមកពី CENAT និងគម្រោង USAID STAR។ សមាជិកនៃគណៈកម្មាធិការស្រាវជ្រាវនេះរួមមាន វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) អង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺសហរដ្ឋអាមេរិក (USCDC) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) សាកលវិទ្យាល័យជាតិសិង្ហបុរី និងអង្គការជាតិ និងអន្តរជាតិដទៃទៀត។

បន្ទាប់ពីការបង្កើតឡើងនៅចុងឆ្នាំ២០២០ CCTBR បានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពស្ថានភាពស្រាវជ្រាវជំងឺរបេងនៅកម្ពុជា បង្ហាញលទ្ធផលស្រាវជ្រាវនៅក្នុងប្រទេស កំណត់របៀបវារៈស្រាវជ្រាវជំងឺរបេងសម្រាប់ប្រទេស និងផ្តល់ធាតុចូលបច្ចេកទេសលើសំណើរសុំស្រាវជ្រាវជំងឺរបេងពីដៃគូ។ CCTBR គួរតែសកម្មក្នុងការរៀបចំឲ្យមានការប្រជុំប្រចាំត្រីមាស។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចប្រជុំថ្មីបំផុត ត្រូវបានកោះប្រជុំ បន្ទាប់ពីរយៈពេលប្រាំបួនខែ ចាប់តាំងពីកិច្ចប្រជុំបានធ្វើឡើង នៅក្នុងខែធ្នូឆ្នាំ ២០២១។ កិច្ចប្រជុំ CCTBR លើកក្រោយនឹងត្រូវបានកំណត់ពេលនៅចុងឆ្នាំ ២០២២។

## 3. របៀបវារៈស្រាវជ្រាវជំងឺរបេង

ក្រោមការដឹកនាំរបស់ NTP នៅខែធ្នូ ឆ្នាំ ២០២១ កិច្ចប្រជុំ CCTBR ត្រូវបានធ្វើឡើងដើម្បីកំណត់អាទិភាពនៃការស្រាវជ្រាវជំងឺរបេងសម្រាប់ឆ្នាំខាងមុខ។ អាទិភាពនៃការស្រាវជ្រាវជំងឺរបេងទាំងនេះនឹងបម្រើជាផែនទីបង្ហាញផ្លូវសម្រាប់ NTP ក្នុងការស្រាវជ្រាវជំងឺរបេង។ អាទិភាពចំនួន ៣០ នៃការស្រាវជ្រាវជំងឺរបេង ក្រោមប្រធានបទចំនួន ៥ ត្រូវបានស្នើឡើងដោយសមាជិករបស់ CCTBR នៅក្នុងកិច្ចប្រជុំខែធ្នូ ឆ្នាំ២០២១៖ ការស្រាវជ្រាវរកករណីជំងឺរបេងចំនួន១២ករណី ការព្យាបាលជំងឺរបេង៤ករណី ការបង្ការជំងឺរបេងចំនួន៩ករណី ជំងឺរបេង/អេដស៍ និងជំងឺទឹកនោមផ្អែមចំនួន៥ករណី និងប្រធានបទផ្សេងៗទៀតដូចជាអត្រាប្រេវ៉ាឡង់ សុខភាពឌីជីថល និងគុណភាពទិន្នន័យ។ របៀបវារៈស្រាវជ្រាវជំងឺរបេង រួមមានការពឹងទុកលើការស្រាវជ្រាវជំងឺរបេងពី NTP និងដៃគូស្រាវជ្រាវរបស់ CCTBR។

របៀបវារៈនៃការស្រាវជ្រាវជំងឺរបេងគឺជាការងារមួយដែលកំពុងដំណើរការដែលនឹងវិវឌ្ឍទៅតាមពេលវេលា និង ត្រូវបានកែសម្រួលដោយ CENAT និង CCTBR ជាបន្តបន្ទាប់។ ផែនការសកម្មភាព (រួមទាំងប្រភពទិន្នន័យ ការរចនាការសិក្សាស្រាវជ្រាវ (study design) និងទីភ្នាក់ងារឈានមុខ) គួរតែត្រូវបានពិភាក្សា និងធ្វើបច្ចុប្បន្នភាពនៅក្នុងកិច្ចប្រជុំ CCTBR ជាទៀងទាត់ ដើម្បីបង្កើតរបៀបវារៈស្រាវជ្រាវជំងឺរបេងឲ្យបានទាន់ពេលវេលា និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ របៀបវារៈនៃការស្រាវជ្រាវ គឺជាឯកសារដែលមានភាពរស់រវើក (living documents) និងតម្រូវឱ្យធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការអភិវឌ្ឍ។ សមាជិក CCTBR បានចងក្រងនូវអាទិភាពនៃការស្រាវជ្រាវដែលមានគូសបញ្ជាក់ក្នុងតារាងទី១ ខាងក្រោម។

**តារាងទី១៖ អាទិភាពស្រាវជ្រាវក្នុងរបៀបវារៈស្រាវជ្រាវជំងឺរបេងដោយ CCTBR (គិតត្រឹមខែឧសភា ឆ្នាំ២០២៣)**

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| **I. ការស្រ្ទីន នឹងការធ្វើរោគវិនិច្ឆ័យ និងការស្រាវជ្រាវរកករណីជំងឺរបេង** | | |
| 1. ដើម្បីស្វែងយល់ពី កត្តាដែលទាក់ទងនឹងការស្រាវជ្រាវរកជំងឺរបេងបេកាបូក តាមទស្សនៈរួមមានជាអាទិ៍៖<br>○ គុណភាពកំហាក នីតិវិធីមន្ទីរពិសោធន៍ និងការអនុវត្ត ភាពអាចរកបាននៃការវិនិច្ឆ័យ សមត្ថភាពបុគ្គលិកថែទាំសុខភាព និងឧបករណ៍ព្យាករណ៍កម្រិតសហគមន៍/បុគ្គលផ្សេងទៀត (individuals/community-level predictor)។ | កំពុងដំណើរការ៖<br>COMMIT និង STAR គ្រោងរៀបចំឯកសារនៃគុណភាពការប្រមូលកំហាក (COMMIT បានផ្តល់ថវិកាមួយចំនួនតូច) | សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល HIV/AIDS (KHANA) និង COMMIT |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| ○ ការប្រៀបធៀបថ្នាក់ខេត្ត និងការបែងចែកតាមក្រុមអាយុ ភេទ និងសមាជិកភាពនៃចំនួនប្រជាជនគន្លឹះៗ។ | | |
| 2. ដើម្បីវាយតម្លៃប្រសិទ្ធភាព និងភាពត្រឹមត្រូវនៃការស្ទ្រីនពិនិត្យ និងវិធីសាស្ត្រធ្វើរោគវិនិច្ឆ័យផ្សេងៗ ដោយប្រើយុទ្ធសាស្ត្រស្ទ្រីននឹងជំងឺរបេងរបស់អង្គការសុខភាពពិភពលោក (ឧ. យុទ្ធសាស្ត្រស្ទ្រីននឹងរោគសញ្ញាចំនួនបួន) និងវិធីសាស្ត្រផ្សេងទៀតដូចជា ការថតសួតដោយកាំរស្មី ប្រូតេអ៊ីន C-reactive វេទិកាវិភាគម៉ូលេគុលៃ ( molecular diagnostic platforms) ការដាក់កំហាកបញ្ចូលគ្នា និងវិធីសាស្ត្រផ្អែកលើភាពមិនមានរោគសញ្ញាក្នុងការរកករណីជំងឺរបេង។ | នៅក្នុងការអង្កេតអត្រាប្រេវ៉ាឡង់ជំងឺរបេងលើកទី៣ អ្នកចូលរួមទាំងអស់នឹងឆ្លងកាត់ការស្ទ្រីននឹង ជាប្រព័ន្ធនូវរោគសញ្ញាជំងឺរបេង និងថតសួតដោយកាំរស្មីអ៊ិច។ យើងអាចប្រើប្រាស់ទិន្នន័យពីការអង្កេតអត្រាប្រេវ៉ាឡង់ជំងឺរបេងជាតិលើកទី៣ បច្ចុប្បន្ន។<br>ត្រូវការពិភាក្សាបន្ថែមជាក្រុមតូចៗ | CENAT |
| 3. ដើម្បីស្វែងយល់ពីឥទ្ធិពលនៃ Algorithms ស្តីពីការរកករណីជំងឺរបេងនៅមូលដ្ឋានសុខាភិបាលថ្នាក់ខេត្ត និងថ្នាក់ជាតិ យុទ្ធនាការស្ទ្រីននឹងពិនិត្យទ្រង់ទ្រាយធំក្នុងសហគមន៍ ទីតាំងដែលមានជំងឺឱកាសនិយម/ព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ (សម្រាប់អ្នកផ្ទុកមេរោគអេដស៍ [PLHIV] កន្លែងគ្រប់គ្រងមនុស្សដែលមានជំងឺផ្សេងទៀត (ជំងឺទឹកនោមផ្អែម មនុស្សចាស់ និងជំងឺរ៉ាំរ៉ៃផ្សេងទៀត) និងក្នុងចំណោមជាក់លាក់ដូចជាកុមារ ស្ត្រីមានផ្ទៃពោះ អ្នកទោស អ្នកជក់បារី អ្នកប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន ជនចំណាកស្រុក អ្នកដែលមានជំងឺផ្លូវចិត្ត អ្នកគ្មានផ្ទះសម្បែង និងអ្នកដែលកង្វះអាហារូបត្ថម្ភ។ | គម្រោងនេះបានបញ្ចប់ហើយ (ស្ថិតក្នុងដំណើរការសរសេរអត្ថបទ) | KHANA/COMMIT |
| 4. ដើម្បីវាយតម្លៃលទ្ធភាពធ្វើបាន និងផលប៉ះពាល់នៃតម្លៃ algorithms និងវិធីសាស្ត្រទាំងនេះ។ | គម្រោងនេះបានបញ្ចប់ហើយ (ស្ថិតក្នុងដំណើរការសរសេរអត្ថបទ) | KHANA/National University of Singapore (NUS) |
| 5. ដើម្បីវាយតម្លៃផលប៉ះពាល់នៃការរួមបញ្ចូលការចុះស្រាវជ្រាវអ្នករស់នៅជិតស្និទ្ធសម្រាប់ TPT ជាមួយនឹងមានសកម្មភាពស្វែងរកករណីជំងឺរបេង | បង្កើតពិធីសារ | COMMIT |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| នៅមណ្ឌលសុខភាព និង សហគមន៍ក្នុងប្រទេសកម្ពុជា។ | | |
| 6. ដើម្បីវាយតម្លៃផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ -១៩ លើការផ្តល់សេវាជំងឺរបេង និងការរីករាលដាលនៃជំងឺរបេង។ | ចងក្រងឯកសារអំពីបញ្ហាប្រឈម និងមេរៀនដែលបានរៀនពីកម្មវិធី COMMIT និង GF ក្នុងអំឡុងពេល COVIDកូវីដ-១៩៖ តាមរយៈការពិនិត្យឯកសារដែលមានស្រាប់ និងការវាយតម្លៃរហ័ស។ | COMMIT/GF |
| 7. ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការស្ទើននឹងពិTranscriptionនិត្យជំងឺរបេងលើទិន្នផលនៃការធ្វើរោគវិនិច្ឆ័យជំងឺរបេងដោយប្រើវិធីផ្សេងគ្នានៃការថតសួតដោយកាំរស្មីរួមមាន៖ ការថតសួតកាំរស្មីឌីជីថលជាមុន ការថតសួតកាំរស្មីម៉ាស៊ីនធម្មតា និងការប្រើប្រាស់ជំនួយកុំព្យូទ័រក្នុងការរកឃើញជំងឺរបេង (ឧ. CAD4TB)។ | ស្វែងរកប្រភពមូលនិធិជាមួយ NUS៖ ជំនួយផ្តួចផ្តើម ៥%? ប្រភពជំនួយផ្សេងទៀត? | |
| 8. ដើម្បីស្វែងយល់ពីតួនាទីរបស់វិស័យឯកជនក្នុងការរកឃើញករណីជំងឺរបេង និងវាយតម្លៃនីតិវិធីប្រតិបត្តិការ ការបញ្ជូន និងដំណើរការរាយការណ៍ពីវិស័យឯកជនទៅកាន់វិស័យសាធារណៈ | KHANA កំពុងពិភាក្សាជាមួយសាកលវិទ្យាល័យស៊ីដនី (Sydney Uni) ដើម្បីធ្វើផែនការសម្រាប់សំណើនេះ | KHANA/Sydney |
| 9. ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការស្វែងរកករណី និងការបញ្ជូនពីវិស័យឯកជន ដើម្បីធ្វើរោគវិនិច្ឆ័យ ព្យាបាល និងថែទាំជំងឺរបេង។ | GF នឹងធ្វើការសិក្សាសាកល្បងដើម្បីពង្រីកតួនាទីរបស់ប្រព័ន្ធចម្រុះរវាង សេវាសាធារណៈ និងឯកជន ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបេង (KHANA នឹងពិភាក្សាជាមួយ NTP លើបញ្ហានេះសម្រាប់ជំនួយបច្ចេកទេស) | GF |
| 10. ការអង្កេតអត្រាប្រេវ៉ាឡង់របេងស៊ាំថ្នាំ (ស្នើឡើងដោយ USAID និងយល់ព្រមដោយនាយក) | ចំណុចនេះនឹងត្រូវបានអនុវត្តជាបណ្តោះអាសន្ននៅឆ្នាំ ២០២៤។ ការពិភាក្សាបន្ថែមជាមួយ CENAT។ | CENAT |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| II. ការព្យាបាលជំងឺរបេង | | |
| 1. ដើម្បីវាយតម្លៃលទ្ធភាពទទួលយកបាន និងលទ្ធភាពធ្វើទៅបាននៃរូបមន្តព្យាបាលរយៈពេល ៤ ខែ សម្រាប់ជំងឺរបេងដែលងាយទទួលថ្នាំ(DS-TB) នៅកម្ពុជា។ | | |
| 2. ដើម្បីស្វែងយល់ពីព័ត៌មាននៃភាពស៊ាំ (Resistance profile) របស់ fluoroquinolones នៅកម្ពុជា ដែលជាអង់ទីប៊ីយ៉ូទិកមួយក្នុងចំណោមថ្នាំអង់ទីប៊ីយោទិចដែលប្រើក្នុងរូបមន្តព្យាបាលរយៈពេល ៤ ខែ។ | | |
| 3. ដើម្បីវាយតម្លៃ pharmacokinetics នៃឱសថដែលប្រើក្នុងរូបមន្តព្យាបាលចំពោះមនុស្សពេញវ័យ កុមារ និងអ្នកដែលមានជំងឺរួមគ្នា។ | | |
| 4. ដើម្បីវាយតម្លៃលទ្ធភាពទទួលយកបាន និងលទ្ធភាពដែលអាចធ្វើទៅបាននៃរូបមន្តព្យាបាលរយៈពេលខ្លី និងមានប្រសិទ្ធភាពជាងដែលត្រូវបានណែនាំដោយ WHO សម្រាប់ជំងឺរបេងដែលស៊ាំនឹងថ្នាំនៅកម្ពុជា។ | បានបញ្ចប់ | CENAT/WHO/COMMIT |
| 5. ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃយន្តការគាំទ្រការព្យាបាលជំងឺរបេងដូចជាវីដេអូ DOTS និង C-DOTS។ | | |
| 6. ដើម្បីវាយតម្លៃយន្តការហិរញ្ញវត្ថុសម្រាប់ការថែទាំជំងឺរបេងនៅក្នុងប្រព័ន្ធវិមជ្ឈការបច្ចុប្បន្ន និងផលវិបាកនៃប្រព័ន្ធលើវិធីបញ្ជូនអ្នកជំងឺ (patients' pathway) រួមទាំងការធ្វើរោគវិនិច្ឆ័យ និងការថែទាំ។ | បានបញ្ចប់ https://gh.bmj.com/content/bmjgh/8/3/e010994.full.pdf | CENAT/WHO/KHANA |
| III. ការព្យាបាលបង្ការជំងឺរបេង | | |
| 1. ដើម្បីវាយតម្លៃប្រសិទ្ធភាពរយៈពេលវែងនៃ TPT ក្នុងការព្យាបាលបង្ការជំងឺរបេងក្នុងចំណោមក្រុមមនុស្សគន្លឹះសម្រាប់ TPT (ឧ. អ្នកផ្ទុកមេរោគអេដស៍ | | |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| អ្នករស់នៅជិតស្និទ្ធជាមួយអ្នកជំងឺរបេងរបេកាបូក)។ | | |
| 2. ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា TPT តាមរយៈការយល់ដឹងកាន់តែប្រសើរឡើងអំពីការព្យាករណ៍ការផ្គត់ផ្គង់ និងតម្រូវការ (ឧ. ការប៉ាន់ប្រមាណទំហំនៃចំនួនអ្នកផ្ទុកមេរោគអេដស៍ និងការគ្របដណ្តប់ TPT ដែលបានព្យាករណ៍ទុក)។ | ការវិភាគទិន្នន័យ។ នឹងបានលទ្ធផលក្នុងខែកញ្ញា សីហា ២០២៣ | Optimizing Latent Tuberculosis Treatment Initiation in Cambodia Among People Living with HIV (OPTICAM) Study by CENAT-NCHADS-IPC-CHAI) |
| 3. ដើម្បីវាយតម្លៃអន្តរកម្មដែលអាចកើតមានរវាងថ្នាំប្រឆាំងមេរោគអេដស៍ និង TPT និងប្រសិទ្ធភាពយូរអង្វែងរបស់ពួកគេក្នុងការព្យាបាលបង្ការជំងឺរបេងក្នុងចំណោមកុមារដែលផ្ទុកមេរោគអេដស៍។ | | |
| 4. ដើម្បីធ្វើប្រតិបត្តិការ និងវាយតម្លៃភាពអាចទទួលយកបាន លទ្ធភាពដែលអាចធ្វើទៅបាន និងប្រសិទ្ធភាពនៃការអនុវត្ត TPT ក្នុងចំណោមអ្នករស់នៅជិតស្និទ្ធជាមួយអ្នករបេងស៊ាំថ្នាំ។ | | |
| 5. ដើម្បីស្វែងយល់ពីឧបសគ្គ និងអ្នកសម្របសម្រួលនៃការទទួលយក TPT ក្នុងចំណោមប្រជាជនគន្លឹះសម្រាប់ TPT (អ្នករស់នៅជិតស្និទ្ធជាមួយអ្នកជំងឺរបេងរបេកាបូក អ្នកផ្ទុកមេរោគអេដស៍) និងបុគ្គលិកថែទាំសុខភាព។ | កំពុងប្រមូលទិន្នន័យ (នឹងបញ្ចប់ក្នុងខែកក្កដា ២០២៣) | KHANA/COMMIT |
| 6. ដើម្បីស្វែងយល់ពីបញ្ហាប្រឈមក្នុងការផ្តល់សេវា TPT តាមទស្សនៈរបស់បុគ្គលិកថែទាំសុខភាព។ | បានបញ្ចប់ https://bmcpulmmed.biomedcentral.com/articles/10.1186/s12890-023-02379-7 | CENAT |
| 7. ដើម្បីស្ទង់អត្រាប្រេវ៉ាឡង់នៃការឆ្លងជំងឺរបេងក្នុងចំណោមប្រជាជនដែលមានហានិភ័យនៃជំងឺរបេង និងវាយតម្លៃភាពត្រឹមត្រូវ ភាពអាចទទួលយកបាន និងលទ្ធភាពដែលអាចធ្វើទៅបាននៃវិធីសាស្ត្រធ្វើតេស្តការឆ្លងជំងឺរបេងផ្សេងៗគ្នា | Proposal development | KHANA/COMMIT/ Sydney |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| ដូចជាការធ្វើតេស្តស្បែក tuberculin និង interferon gamma release assay។ | | |
| 8. ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃ TPT ក្នុងចំណោមស្ត្រីមានផ្ទៃពោះ និងទារកដែលមានសិទ្ធិទទួលបាន TPT។ | | |
| IV. **ផ្សេងៗ៖ ប្រេវ៉ាឡង់ជំងឺរបេង សុខភាពឌីជីថល និងសុខមាលភាពក្រោយជំងឺរបេង និងគុណភាពទិន្នន័យ** | | |
| 1. ដើម្បីប៉ាន់ប្រមាណអត្រាប្រេវ៉ាឡង់នៃជំងឺរបេងក្នុងចំណោមប្រជាជនគន្លឹះៗសម្រាប់ជំងឺរបេង (ឧ. អ្នកទោស អ្នកគ្មានផ្ទះសម្បែង មនុស្សចាស់ អ្នករស់នៅជិតស្និទ្ធជាមួយអ្នកជំងឺរបេង អ្នកដែលប្រើប្រាស់ថ្នាំញៀន និងអ្នកដែលចាក់ថ្នាំ ការយល់ឃើញពីហានិភ័យ និងកត្តាដែលប៉ះពាល់ដល់អាកប្បកិរិយាស្វែងរកការថែទាំរបស់ពួកគេ។ | | |
| 2. ដើម្បីវាយតម្លៃលទ្ធភាព និងប្រសិទ្ធភាពនៃការបញ្ចូលបច្ចេកវិទ្យាចល័តក្នុងការកែលម្អចំណេះដឹងអំពីជំងឺរបេង អាកប្បកិរិយាស្វែងរកការថែទាំ និងការគាំទ្រការព្យាបាល។ | | |
| 3. ដើម្បីវាយតម្លៃសុខភាពក្រោយកើតជំងឺរបេង និងសុខុមាលភាពរបស់មនុស្សដែលមានជំងឺរបេង។ | លទ្ធផលបឋម | KHANA/COMMIT |
| 4. ដើម្បីវាយតម្លៃភាពអាចទទួលយកបាន បទពិសោធន៍អ្នកប្រើប្រាស់ និងលទ្ធភាពដែលអាចធ្វើទៅបាននៃការបញ្ចូលបច្ចេកវិទ្យាព័ត៌មានសុខភាព ដើម្បីកែលម្អគុណភាពទិន្នន័យជំងឺរបេងនៅថ្នាក់មណ្ឌលសុខភាព និងសហគមន៍។ | | |
| V. **ការផ្តល់ហិរញ្ញប្បទានរបេង និងនិរន្តរភាព** | | |
| 1. ការអង្កេតស្តីពីតម្លៃចំពោះអ្នកជំងឺរបេងថ្នាក់ជាតិ (ត្រូវធ្វើឡើងនៅឆ្នាំ 2023) | NECHR-បានអនុម័តហើយ ការប្រមូលទិន្នន័យក្នុងខែកក្កដា - សីហា ឆ្នាំ 2023 | LHSS |

| ប្រធានបទស្រាវជ្រាវ | ស្ថានភាពក្នុងឆ្នាំ២០២៣ | ដៃគូអនុវត្ត |
|---|---|---|
| 2. ឯកសារនៃការអនុវត្តម៉ូដែលជំងឺរបេងតាមសហគមន៍ដោយផ្ដោតការយកចិត្តទុកដាក់របស់ឃុំ/សង្កាត់ (ក្នុងខេត្ត២-៤) | ផែនការបានបញ្ចប់សម្រាប់ស្រុកប្រតិបត្តិ១ (កងមាស) | LHSS |
| 3. ការធ្វើផែនទីមូលនិធិជំងឺរបេង និងការវិភាគគម្លាតនៅក្នុងខេត្ត កំពង់ចាម និងស្វាយរៀង (២០២២) | បានបញ្ចប់ | LHSS |
| 4. ការវិភាគហិរញ្ញវត្ថុសម្រាប់ការចំណាយដែលត្រូវការសម្រាប់ការរួមបញ្ចូលសេវាជំងឺរបេងនៅក្នុងកញ្ចប់មូលនិធិសង្គម របបសន្តិសុខសង្គម (មិនទាន់មានការកំណត់ពេលវេលានៅឡើយទេ) | | |

# 4. ការបង្កើតពិធីសារស្រាវជ្រាវ

ការអភិវឌ្ឍពិធីសារស្រាវជ្រាវ គឺជាជំហានសំខាន់សម្រាប់អ្នកស្រាវជ្រាវដើម្បី៖

- បញ្ជាក់គោលបំណងសិក្សាស្រាវជ្រាវ
- បង្កើតសម្មតិកម្មស្រាវជ្រាវដែលអាចជឿទុកចិត្តបាន
- អភិវឌ្ឍការរចនាការសិក្សា
- ពន្យល់ពីទិដ្ឋភាពទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៃវិធីសាស្ត្រ
- រៀបចំផែនការវិភាគទិន្នន័យត្រឹមត្រូវ និងមានប្រសិទ្ធភាព។
- ពណ៌នាអំពីលទ្ធផលរំពឹងទុក និង
- ផ្តល់ផែនការក្រមសីលធម៌ស្រាវជ្រាវដែលរៀបចំបានល្អផ្នែកការពារអ្នកជំងឺ។

ទម្រង់ស្តង់ដារនៃពិធីសារស្រាវជ្រាវគួរតែរួមបញ្ចូលនូវសមាសធាតុ និងព័ត៌មានដូចខាងក្រោម៖

## 4.1. ចំណងជើងគម្រោង

ចំណងជើងគម្រោងស្រាវជ្រាវគួរតែខ្លី ជាក់លាក់ និងផ្តល់ព័ត៌មាន។ ប្រវែងនៃចំណងជើងត្រូវបានកំណត់ត្រឹម ១៥០ តួអក្សរសម្រាប់គម្រោងស្រាវជ្រាវមួយ។ អ្នកស្រាវជ្រាវមិនគួរប្រើចំណងជើងមានលក្ខណៈទូទៅពេក ចំណងជើងបែបប្រកាស ចំណងជើងដែលរួមមានទិសដៅនៃលទ្ធផលសិក្សា ឬសំណួរជាចំណងជើង។ សម្រាប់ការសាកល្បងព្យាបាល ការវិភាគទិន្នន័យរួមគ្នាច្រើន (meta-analyses) និងការពិនិត្យឡើងវិញជាប្រព័ន្ធ គម្រោងអាចរួមបញ្ចូលប្រភេទនៃការសិក្សាជាចំណងជើងរង (subtitle) ដូចជា "ការសាកល្បងព្យាបាលលក្ខណៈចៃដន្យ (A Randomized Clinical Trial)", "ការវិភាគទិន្នន័យរួមគ្នាច្រើន (Meta-analysis)" ឬ "ការពិនិត្យឡើងវិញជាប្រព័ន្ធ"។ សម្រាប់ប្រភេទស្រាវជ្រាវផ្សេងទៀត អ្នកស្រាវជ្រាវមិនគួររួមបញ្ចូលប្រភេទ ឬការរចនាការសិក្សានៅក្នុងចំណងជើង ឬចំណងជើងរងឡើយ។

## 4.2. បញ្ជីអ្នកសិក្សាស្រាវជ្រាវ

អ្នកស្រាវជ្រាវចម្បង (Principal Investigator, PI) និង Co-PIs គួរតែមានយ៉ាងហោចណាស់ ការស្រាវជ្រាវកម្រិតខ្ពស់ ឬសញ្ញាបត្រវេជ្ជសាស្ត្រ (ឧទាហរណ៍ បណ្ឌិត ឬវេជ្ជបណ្ឌិត) ឬសញ្ញាបត្រអនុបណ្ឌិតដែលមានបទពិសោធន៍ស្រាវជ្រាវយ៉ាងទូលំទូលាយ។ ពួកគេត្រូវបានគេសន្មត់ថា នឹងធ្វើការរួមចំណែកយ៉ាងសំខាន់ ក្នុងគំនិតស្រាវជ្រាវ ការរចនាការសិក្សា ការទាញយកទិន្នន័យ (data acquisition) ការវិភាគទិន្នន័យ ឬការបកស្រាយយ៉ាងសំខាន់អំពីទិន្នន័យសម្រាប់គម្រោងស្រាវជ្រាវ។ PI ឬ Co-PI នីមួយៗគួរតែរាយបញ្ជីជាមួយនឹងសញ្ញាបត្រសិក្សា និងទំនាក់ទំនងរបស់ពួកគេ។ អ្នកស្រាវជ្រាវបន្ទាប់បន្សំអាចត្រូវបានរាយបញ្ជី ប្រសិនបើពួកគេផ្តល់កិច្ចសហការដ៏សំខាន់ដល់គម្រោង។ ជីវប្រវត្តិសិក្សា (CV) សម្រាប់ PI, Co-PIs, និងអ្នកស្រាវជ្រាវផ្សេងទៀតគួរតែបញ្ចូលក្នុងឧបសម្ព័ន្ធ។

## 4.3. សេចក្តីសង្ខេបអំពីការស្រាវជ្រាវ

អ្នកស្រាវជ្រាវគួរតែប្រើចំណងជើងខាងក្រោមនៅក្នុងសេចក្តីសង្ខេបអំពីការសិក្សា៖ សាវតារ វត្ថុបំណងនៃការសិក្សា វិធីសាស្រ្ត លទ្ធផលរំពឹងទុក និងក្រុមសីលធម៌ស្រាវជ្រាវ។ ជាការសង្ខេប ផ្នែកនៃសេចក្តីសង្ខេបរបស់ការសិក្សាអាចត្រូវបានសរសេរជាឃ្លាជាជាងប្រយោគពេញលេញ។ ចំនួនពាក្យជាទូទៅសម្រាប់សេចក្តីសង្ខេបអំពីការសិក្សានេះនឹងមានប្រហែល ២៥០-៣០០ ពាក្យ។

សេចក្តីសង្ខេបគួរតែចាប់ផ្តើមដោយប្រយោគមួយ ឬពីរដែលពន្យល់ពីសារៈសំខាន់នៃអេពីដេមីសាស្រ្ត ឬសារៈសំខាន់គ្លីនិកនៃសំណួរនៃការសិក្សាស្រាវជ្រាវដែលបានស្នើឡើងនេះ។ ត្រូវបញ្ជាក់វត្ថុបំណងច្បាស់លាស់ ឬសំណួរនៃការសិក្សាស្រាវជ្រាវដែលមាននៅក្នុងរបាយការណ៍៖ ឧ. "ដើម្បីកំណត់ថាតើ..."

វិធីសាស្រ្តរួមមាន ការរចនាវិធីជ្រើសរើសសំណាកមូលដ្ឋាន (basic sampling design) និងប្រភេទសិក្សាជាក់លាក់ (specific study type) ឧ. ការសាកល្បងព្យាបាលចៃដន្យ (randomized clinical trial), cohortរយៈពេលវែងលើក្រុមជាក់លាក់ ឯករវលា លក្ខណៈគ្រប់គ្រងករណី ករណីជាសេរី ការសង្កេត ឬការវិភាគទិន្នន័យរួមគ្នាច្រើន, cross-sectional, case-control, case series, survey, ឬ meta-analysis។ រយៈពេលនៃការសិក្សាដែលបានស្នើឡើងគួរតែត្រូវបានរួមបញ្ចូលផងដែរ។

លទ្ធផលរំពឹងទុក និងភាពពាក់ព័ន្ធគួរតែត្រូវបានសង្ខេប ដើម្បីផ្តល់សេចក្តីបញ្ជាក់អំពីភាពពាក់ព័ន្ធដែលបង្ហាញពីផលប៉ះពាល់សម្រាប់ការអនុវត្តបែបគ្លីនិក (clinical practice) ឬគោលនយោបាយសុខភាព។

## 4.4. សាវតារ/សេចក្តីផ្តើម

ផ្នែកសាវតារ គឺមានប្រហែល ១៥០-២៥០ ពាក្យ។ ប្រយោគ ២ ទៅ ៣ ដំបូងនៃសេចក្តីផ្តើម គួរតែបង្កើតសារៈសំខាន់នៃការសិក្សាដែលបានស្នើឡើងនេះ។ កថាខណ្ឌទី១ គួរតែផ្តល់នូវសេចក្តីសង្ខេបទូទៅអំពីបញ្ហាគ្លីនិក(clinical issue) ឬបញ្ហាអេពីដេមីសាស្រ្ត (ឧ. ជំងឺរបេង)។ កថាខណ្ឌបន្ទាប់ គួរតែផ្តោតលើទិដ្ឋភាពជាក់លាក់នៃសុខភាពសាធារណៈ ឬបញ្ហាគ្លីនិកដែលការសិក្សានឹងស្វែងយល់ (ឧ. ការធ្វើរោគវិនិច្ឆ័យជំងឺរបេង)។ អេពីដេមីសាស្រ្តនៃជំងឺ ឬស្ថានភាពណាមួយ គួរតែត្រូវបានសង្ខេបខ្លី និងជាទូទៅគួរតែរួមបញ្ចូលនូវអត្រាប្រេវ៉ាឡង់ និងអាំងស៊ីដង់នៃជំងឺផង។ កថាខណ្ឌទី៣ គួរតែពិភាក្សាឱ្យច្បាស់ថា តើសម្ភារៈអ្វីខ្លះនឹងត្រូវបានរុករកនៅក្នុងការសិក្សានេះ (ឧ. វិធីសាស្រ្ត និងលទ្ធភាពប្រើប្រាស់បាននៅក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបេង)។

ការស្វែងរកឯកសារ (literature search) គួរតែរកឯកសារថ្មីៗតាមដែលអាចធ្វើទៅបាន លើកលែងការបោះពុម្ពផ្សាយការស្រាវជ្រាវដែលមានលក្ខណៈដាច់ដោយឡែកប៉ុណ្ណោះ (distinguished research publications)។ ការស្វែងរកឯកសារបឋម (primary literature) គួរតែធ្វើឡើងដោយរួមទាំងមូលដ្ឋានទិន្នន័យគន្ថនិទ្ទេសចម្រុះ (multiple bibliographic databases) (ឧ. PubMed/MEDLINE,

Embase, CINAHL, PsycINFO) ។ ភស្តុតាងដែលមានគុណភាពខ្ពស់បំផុត (ឧ. ការសាកល្បងព្យាបាលចៃដន្យ ការវិភាគទិន្នន័យរួមគ្នាច្រើន ការត្រួតពិនិត្យជាប្រព័ន្ធ និងការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ដែលមានគុណភាពខ្ពស់ (high-quality prospective cohort studies) គួរតែទទួលបានការយកចិត្តទុកដាក់ខ្លាំងបំផុត។ គោលការណ៍ណែនាំការអនុវត្តគ្លីនិក (Clinical practice guidelines) ជាធម្មតា មិនត្រូវបានប្រើប្រាស់ ជាធាតុផ្សំចម្បងនៃមូលដ្ឋានភស្តុតាងសម្រាប់វិវេចនាសាស្ត្រ (literature review) នោះទេ។

ជាជាងគ្រាន់តែជាការសង្ខេបអំពីការស្រាវជ្រាវដែលត្រូវបានបោះពុម្ពផ្សាយមុន ផ្នែកសារវតារគួរតែបង្ហាញការយល់ដឹងទូលំទូលាយអំពីរបៀបដែលឯកសារ (literature) ត្រូវគ្នា និងនាំឱ្យមានការស្រាវជ្រាវបច្ចុប្បន្ននេះ។ សារវតារ ឬសេចក្តីផ្តើម គួរតែរួមបញ្ចូលឯកសារបរិមាណវិស័យ និង/ឬគុណភាពដែលពាក់ព័ន្ធលើប្រធានបទស្រាវជ្រាវ។ ជួនកាលយកល្អត្រូវប្រកាន់យកគោលជំហរសំខាន់មួយឆ្ពោះទៅរកការស្រាវជ្រាវដែលមានស្រាប់ និងគួសបញ្ជាក់ពីចន្លោះប្រហោង ឬដែនកំណត់វិធីសាស្ត្រ ទន្ទឹមនឹងនោះក៏គូសបញ្ជាក់ពីសារៈសំខាន់នៃស្រាវជ្រាវពីមុនដែលផ្តល់ព័ត៌មានដល់ការរចនាការសិក្សាស្រាវជ្រាវផ្ទាល់ខ្លួនរបស់អ្នក។

## 4.5. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងស្រាវជ្រាវ ចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅពេលចាប់ផ្តើមគម្រោង (គំនិតប្រធានបទ និងដំណាក់កាលសំណើ)។ គោលបំណងស្រាវជ្រាវ និងសំណួរស្រាវជ្រាវ កំណត់ការផ្តោតការយកចិត្តទុកដាក់ និងវិសាលភាពនៃគម្រោងស្រាវជ្រាវរបស់អ្នក។ ចំណុចទាំងនោះជួយក្នុងការកម្រិតវិសាលភាពនៃការស្រាវជ្រាវរបស់អ្នក ដូច្នេះអ្នកអាច "ចូលជ្រៅ" និងស្វែងយល់ឱ្យបានហ្មត់ចត់នូវបញ្ហា ឬឱកាសជាក់លាក់ណាមួយ។ គោលបំណងនៃការស្រាវជ្រាវទាំងនោះក៏ជួយឱ្យអ្នកដើរត្រូវផ្លូវផងដែរ ព្រោះវាដើរតួជាការសាកល្បងរកភាពពាក់ព័ន្ធ។ ម្យ៉ាងវិញទៀត ប្រសិនបើអ្នកមិនប្រាកដថាត្រូវបញ្ចូលអ្វីមួយក្នុងការស្រាវជ្រាវរបស់អ្នកទេ គ្រាន់តែសួរខ្លួនឯងនូវសំណួរ "តើចំណុចនេះរួមចំណែកដល់គោលបំណងនៃការស្រាវជ្រាវរបស់ខ្ញុំដែរឬទេ?"

អ្នកស្រាវជ្រាវ គួរតែបញ្ជាក់ពីគោលបំណងច្បាស់លាស់ ឬសំណួរសិក្សាដែលបានលើកឡើងនៅក្នុងការសិក្សា៖ ឧ. "ដើម្បីកំណត់ថាតើ..."។ ប្រសិនបើគោលបំណងច្រើនជាងមួយត្រូវដោះស្រាយនោះ គោលបំណង សំខាន់ គួរតែត្រូវបានចង្អុលបង្ហាញ ហើយមានតែគោលបំណងបន្ទាប់បន្សំសំខាន់ៗប៉ុណ្ណោះ ដែលបានបញ្ជាក់។ ប្រសិនបើសម្មតិកម្មមុន(priori hypothesis)ត្រូវបានគេស្តនោះ វាគួរតែត្រូវបានបញ្ជាក់។

គោលបំណងស្រាវជ្រាវត្រូវពណ៌នាអំពីអ្វីដែលអ្នកមានបំណងចង់ឱ្យគម្រោងស្រាវជ្រាវរបស់អ្នកសម្រេចបាន។ វត្ថុបំណងទាំងនោះជួយឱ្យអ្នកផ្តើតលើការសិក្សារបស់អ្នកដោយផ្តល់នូវទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ

និងគោលដៅរបស់គម្រោង។ ការចាប់ផ្ដើមនៃពិធីសារស្រាវជ្រាវរបស់អ្នក គួរតែរួមបញ្ចូលគោលបំណងរបស់អ្នកបន្ទាប់ពីសេចក្ដីថ្លែងអំពីចំណោទបញ្ហា (problem statement) នៅពេលចាប់ផ្ដើមរបៀបវារៈនៃការស្រាវជ្រាវរបស់អ្នក។

គោលបំណងអាចមានលក្ខណៈទូទៅ ឬជាក់លាក់។ គោលបំណងទូទៅនៃការសិក្សារបស់អ្នកពណ៌នាអំពីអ្វីដែលអ្នកសង្ឃឹមថានឹងសម្រេចបានក្នុងដំណាក់កាលទូលំទូលាយទូទៅ (broad strokes)។ បំណងជាក់លាក់បែងចែកគោលដៅរួមទៅជាផ្នែកតូចៗ ដែលទាក់ទងគ្នាទៅវិញទៅមក ប្រកបដោយតក្កវិជ្ជា (logically interconnected) ដែលដោះស្រាយយ៉ាងល្អិតល្អន់លើផ្នែកផ្សេងៗនៃបញ្ហា។ គោលបំណងជាក់លាក់របស់អ្នកគួរលម្អិតយ៉ាងជាក់លាក់ នូវអ្វីដែលអ្នកនឹងធ្វើក្នុងដំណាក់កាលនីមួយៗនៃការសិក្សារបស់អ្នក ក៏ដូចជានៅពេលណា កន្លែងណា ហេតុអ្វី និងរបៀបយ៉ាងម៉េច។

គោលបំណងស្រាវជ្រាវគួរតែត្រូវបានបង្កើតឡើងជាមួយនឹងលក្ខណៈវិនិច្ឆ័យ "SMART"៖

ជាក់លាក់ (Specific)៖ អ្នកណាពាក់ព័ន្ធ? តើអ្នកចង់សម្រេចអ្វី?

ភាពអាចវាស់វែងបាន (Measurable)៖ តើវាអាចប្រមាណបានទេ ហើយតើអ្នកអាចវាស់វែងវាបានទេ?

ភាពអាចសម្រេចបាន (Achievable)៖ តើអ្នកអាចធ្វើវាបាននៅក្នុងពេលវេលាដែលបានស្នើឡើងជាមួយនឹងធនធាន និងការគាំទ្រដែលអ្នកមានឬទេ?

ភាពពាក់ព័ន្ធ (Relevant)៖ តើគោលបំណងនេះមានឥទ្ធិពលលើគោលដៅ ឬយុទ្ធសាស្ត្រដែលចង់បានដែរឬទេ?

ពេលវេលាកំណត់ (Time bound)៖ តើគោលដៅនេះនឹងសម្រេចនៅពេលណា?

## 4.6. វិធីសាស្ត្រ

ដើម្បីរៀបចំផែនការ និងធ្វើការស្រាវជ្រាវជំងឺរបេង អ្នកស្រាវជ្រាវគួរតែមានចំណេះដឹងទូលំទូលាយ ឬបានទទួលការបណ្ដុះបណ្ដាលស៊ីជម្រៅក្នុងវិធីសាស្ត្រស្រាវជ្រាវ។ នៅក្នុងផ្នែកវិធីសាស្ត្រនៃពិធីសារការស្រាវជ្រាវ អ្នកស្រាវជ្រាវ គួរតែបង្ហាញការរចនាការស្រាវជ្រាវរបស់ពួកគេ ដោយផ្អែកលើវិធីសាស្ត្រស្រាវជ្រាវ ដូចខាងក្រោម៖

### 4.6.1. វិធីសាស្ត្របរិមាណវិស័យ

ការស្រាវជ្រាវបរិមាណវិស័យ គឺជាដំណើរការនៃការប្រមូល និងវិភាគទិន្នន័យជាលេខ។ វាអាចត្រូវបានប្រើដើម្បីស្វែងរកលំនាំ (patterns) និងមធ្យមភាគ (averages) ដើម្បីធ្វើការទស្សន៍ទាយ (make predictions) ផ្ទៀងផ្ទាត់ទំនាក់ទំនងដែលបង្កហេតុ (verify causal linkages) និងធ្វើឱ្យលទ្ធផលទូទៅទៅកាន់ប្រជាជនចំនួនច្រើនជាង(larger populations)។ ចាំបាច់ណាស់ក្នុងការពណ៌នាអំពីការរចនាជាមូលដ្ឋាននៃការសិក្សា និងរួមបញ្ចូលប្រភេទការសិក្សាជាក់លាក់៖

1. **ការសិក្សាឯកវេលា** (Cross-sectional study)

- ការសង្កេតជាធម្មតា ការសិក្សាឯកវេលា (cross-sectional studies) បានផ្តល់នូវសេចក្តីសង្ខេបនៃចារិកលក្ខណៈនៃប្រធានបទនៅចំណុចមួយក្នុងពេលវេលាណាមួយ។
- ការសិក្សាឯកវេលា (Cross-sectional studies) មិនដូចការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort studies) ទេ គឺមិនមានរយៈពេលតាមដាន ដូច្នេះហើយវាហាក់ដូចជាងាយស្រួលធ្វើ។
- ដោយសារស្ថានភាពនៃការប្រឈម/លទ្ធផលនៃព័ត៌មានចំណាប់អារម្មណ៍ ត្រូវបានប្រមូលនៅចំណុចតែមួយក្នុងពេលវេលា ជាធម្មតាតាមរយៈការស្ទង់មតិ (surveys) ការរចនាការសិក្សាឯកវេលា cross-sectional study design គឺជាការរចនាសង្កេតដែលខ្សោយបំផុត ព្រោះវាមិនអាចបង្កើតទំនាក់ទំនងបែបហេតុផល (cause-effect relationship)។
- ការរចនាការសិក្សានេះ ជាធម្មតាត្រូវបានអនុវត្តដើម្បីកំណត់អត្រាប្រេវ៉ាឡង់នៃជំងឺនៅក្នុងក្រុមមនុស្សមួយ។

2. **ការសិក្សារយៈពេលវែងលើក្រុមជាក់លាក់** (Cohort study)

- ការចាត់ថ្នាក់អ្នកជំងឺដំបូងនៅក្នុងការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ cohort studies គឺផ្អែកលើស្ថានភាពនៃការប៉ះពាល់ ឬការប្រឈមរបស់ពួកគេ។
- ពេលវេលាចេះតែកន្លងទៅ ក្រុមជាក់លាក់ (cohort) ត្រូវបានត្រួតពិនិត្យតាមដានដើម្បីកំណត់ថាតើនរណានៅក្នុងក្រុមដែលប៉ះពាល់ និងមិនប៉ះពាល់កើតជំងឺនេះ។
- ទាំងការវិភាគលើក្រុមជាក់លាក់រយៈពេលវែងត្រឡប់ក្រោយ និងរយៈពេលវែងទៅមុខ បែប retrospective cohort និង prospective cohort គឺអាចធ្វើទៅបាន។
- អាំងស៊ីដង់អាចត្រូវបានគណនាដោយផ្ទាល់ពីការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort studies) ព្រោះវាចាប់ផ្តើមជាមួយអ្នកជំងឺដែលបានប៉ះពាល់ និងមិនបានប៉ះពាល់ ចំណែកការសិក្សាដែលមានការគ្រប់គ្រងករណី (case-control study) ចាប់ផ្តើមជាមួយបុគ្គលដែលមានជំងឺ និងមានសុខភាពល្អ។
- នៅក្នុងការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort study) ការវាស់វែងឥទ្ធិពលមានហានិភ័យបន្តិចបន្តួច។
- ភាពលំអៀងដោយសារការចងចាំ (Recall bias) គឺមានកម្រិតទាបបំផុតនៅក្នុងការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort studies) ហើយលទ្ធផលជាច្រើនអាចត្រូវបានស៊ើបអង្កេតក្នុងពេលដំណាលគ្នា។

- គុណវិបត្តិនៃការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort studies) គឺថាពួកគេងាយនឹងមានភាពលំអៀងក្នុងការជ្រើសរើស។
- ការប្រើប្រាស់ការសិក្សារយៈពេលវែងលើក្រុមជាក់លាក់ (cohort studies) ដើម្បីស៊ើបអង្កេតជំងឺកម្រ និងលទ្ធផលដែលមានរយៈពេលតាមដានយូរ អាចមានតម្លៃថ្លៃ និងចំណាយពេលច្រើន។

3. **ការសិក្សាដែលមានការគ្រប់គ្រងករណី** (Case-control study)

- វាត្រូវបានអនុវត្តដើម្បីវាយតម្លៃភាពខ្លាំងនៃទំនាក់ទំនងរវាងកត្តាហានិភ័យ (risk factors) និងលទ្ធផល (outcomes)។ ការប៉ះពាល់គឺជាកត្តាដែលជះឥទ្ធិពលដល់ហានិភ័យកើតជំងឺ។
- ការសិក្សាដែលមានការគ្រប់គ្រងករណី (Case-control studies) អាចជួយកំណត់ថាតើការប៉ះពាល់គឺមានប្រយោជន៍ (beneficial) ឬធ្វើឱ្យជុនដាប់ (detrimental)។
- អ្នកជំងឺមានពីរប្រភេទ៖ ករណី (cases) និងកុងត្រូល (controls)។ អ្នកជំងឺដែលមានជំងឺស្ថានភាព ឬពិការភាពជាក់លាក់គឺ ជាករណី។ អ្នកជំងឺដែលមិនមានជំងឺនេះត្រូវបានគេហៅថាកុងត្រូល។
- អ្នកស្រាវជ្រាវកំណត់ឲ្យបានតំណាងគ្រប់គ្រាន់នៃកុងត្រូលពីប្រជាជនទូទៅសម្រាប់ករណីដែលពួកគេកំពុងសិក្សា។ បន្ទាប់មក ពួកគេធ្វើការស៊ើបអង្កេតលើលទ្ធភាពដែលអ្នកជំងឺទាំងនេះអាចប្រឈមមុខនឹងកត្តាហានិភ័យកាលពីអតីតកាល។
- ការជ្រើសរើសអ្នកជំងឺសម្រាប់ក្រុមកុងត្រូលគឺជាទិដ្ឋភាពសំខាន់នៃការស្រាវជ្រាវដែលមានការគ្រប់គ្រងករណី (case-control research)។
- ការសិក្សាដែលមានការគ្រប់គ្រងករណី (Case-control studies) គឺងាយនឹងមានភាពលំអៀងដោយសារការចងចាំ (Recall bias) ដោយសារតែលក្ខណៈនៃការមើលថយក្រោយនៃការរចនារបស់ពួកគេ។
- ការសិក្សាដែលមានការគ្រប់គ្រងករណី (Case-control studies) គឺចំណាយតិច មានប្រសិទ្ធភាព និងលឿនជាងក្នុងការអនុវត្ត។ ការរចនាការសិក្សានេះគឺសមស្របជាពិសេសសម្រាប់ជំងឺមិនធម្មតាដែលមានរយៈពេលសម្ងំយូរ។

4. **ការសាកល្បងព្យាបាលបែបចៃដន្យ** (Randomized clinical trial)

- បុគ្គលគោលដៅស្រាវជ្រាវ (Research subjects) ត្រូវបានដាក់ចូលដោយចៃដន្យទៅក្រុមកុងត្រូល ដែលមានការគ្រប់គ្រង និងក្រុមពិសោធន៍ (experimental group)។
- ការជ្រើសរើសដោយចៃដន្យក្នុងការសាកល្បងដែលមានការគ្រប់គ្រងដោយចៃដន្យ (randomized controlled trials) អាចការពារការភ័ន្តច្រឡំ និងកាត់បន្ថយភាពលំអៀងដោយជម្រើស។ ចំណុចនេះអនុញ្ញាតឱ្យអ្នកស្រាវជ្រាវមានក្រុមពិសោធន៍ និងការកុងត្រូលដែលអាចប្រៀបធៀបបាន ដោយអនុញ្ញាតឱ្យពួកគេកំណត់ឥទ្ធិពលនៃអន្តរាគមន៍។
- ក្រុមពិសោធន៍ (experimental group) ទទួលបានការប៉ះពាល់/ការព្យាបាល ដែលអាចជាភ្នាក់ងារបង្ករជំងឺ បង្ការជំងឺ ឬព្យាបាលជំងឺ។
- អាស្រ័យលើគោលបំណងនៃការសិក្សា ក្រុមកុងត្រូលគ្រប់គ្រងមិនទទួលបានការព្យាបាល ថ្នាំសាកល្បង (placebo) ឬស្តង់ដារនៃការព្យាបាលថៃទាំផ្សេងទៀតទេ។
- បន្ទាប់មកក្រុមទាំងពីរនេះត្រូវបានគេសង្កេតមើលនាពេលអនាគត ដើម្បីកំណត់ថាតើអ្នកណាបង្កើតលទ្ធផលដែលចង់បាន។
- សុចរិតភាពការជ្រើសរើសដោយចៃដន្យ (randomization integrity) ត្រូវបានប៉ះពាល់ជាញឹកញាប់ដោយការបដិសេធ (refusals) ការបោះបង់ (dropouts) ការឆ្លងកាត់ (crossovers) និងការមិនអនុលោមតាមច្បាប់ (noncompliance)។
- ការរចនាការសិក្សានេះមានតម្លៃថ្លៃ ហើយអ្នកស្រាវជ្រាវដែលប្រើការរចនាការសិក្សានេះតែងតែជួបប្រទះបញ្ហាជាមួយនឹងការបដិសេធ ការបោះបង់ ការឆ្លងកាត់ និងការមិនអនុលោមតាមច្បាប់។

5. **ពិសោធនូបចារ៍ (Quasi experiment)**

- គឺជាការរួមបញ្ចូលនូវភាពចម្រុះនៃការសិក្សាអន្តរាគមន៍មិនចៃដន្យ (nonrandomized intervention studies)។ នៅពេលដែលវាមិនអាចអនុវត្តបាន ឬគ្មានក្រមសីលធម៌ក្នុងការធ្វើការសាកល្បងដែលមានការគ្រប់គ្រងចៃដន្យ (randomized controlled trial) ការរចនាទាំងនេះត្រូវបានប្រើប្រាស់ជាញឹកញាប់។
- វាត្រូវបានគេស្គាល់ផងដែរថាការរចនាមុន-ក្រោយការអន្តរាគមន៍ (pre-post intervention design) ត្រូវបានប្រើប្រាស់ជាញឹកញាប់ក្នុងវិស័យស្រាវជ្រាវសុខភាព ក្នុងគោលបំណងកំណត់ពីប្រសិទ្ធភាពនៃអន្តរាគមន៍ផ្សេងៗ។
- ទោះបីជា ការសាកល្បងដែលមានការគ្រប់គ្រងចៃដន្យ (randomized controlled trial) ត្រូវបានគេគិតថាជាវិធីដែលអាចទុកចិត្តបំផុតដើម្បីកំណត់មូលហេតុ និងឥទ្ធិពលក៏ដោយ ក៏អ្នកស្រាវជ្រាវតែងតែជ្រើសរើសមិនធ្វើអន្តរាគមន៍ដោយចៃដន្យទេ ដោយសារហេតុផលមួយ

ឬច្រើនដូចខាងក្រោម៖ កង្វល់ខាងក្រមសីលធម៌
ភាពលំបាកក្នុងការចាត់តាំងបុគ្គលគោលដៅដោយចៃដន្យ
ភាពលំបាកក្នុងការចាត់តាំងទីកន្លែងដោយចៃដន្យ និងចំនួនសំណាកដែលមានតិចតួច។

6. **របាយការណ៍ករណី (Case report)**
   - របាយការណ៍ករណី ស៊េរីករណី (case series) និងការស្រាវជ្រាវករណីសិក្សា (case study research)
     គឺជាវិធីសាស្ត្របែបពណ៌នាសម្រាប់បង្ហាញអ្នកជំងឺនៅក្នុងបរិយាកាសគ្លីនិកតាមដំណើរបែបធម្មជាតិរបស់ពួកគេ (their natural clinical environment)។
   - របាយការណ៍ករណី ដែលជាធម្មតាមានអ្នកជំងឺបីនាក់ ឬតិចជាងនេះ
     ត្រូវបានសរសេរដើម្បីបង្ហាញពីទិដ្ឋភាពនៃការអនុវត្តផ្នែកវេជ្ជសាស្ត្រ
     និងដើម្បីបង្កើតសំណួរស្រាវជ្រាវថ្មី ដែលអាចរួមចំណែកដល់ការពង្រីកផ្នែកឯកសារ
     (literature)។
   - អ្នកជំងឺជាច្រើនត្រូវបានចូលរួមនៅក្នុងករណីសិក្សា ដែលជាវិធីសាស្ត្រស្រាវជ្រាវគុណវិស័យ
     ដែលរួមបញ្ចូលការវិភាគស៊ីជម្រៅ ឬការសាកសួរបទពិសោធន៍អំពីបុគ្គល ឬក្រុមនៅក្នុងបរិយាកាសបែបធម្មជាតិរបស់ពួកគេ (their natural environment)។
   - ការស្រាវជ្រាវករណីសិក្សា សង្កត់ធ្ងន់លើការវិភាគបរិបទនៃព្រឹត្តិការណ៍ ឬលក្ខខណ្ឌជាច្រើន
     និងទំនាក់ទំនងគ្នាទៅវិញទៅមករបស់ពួកគេ (their interrelationships)។
   - ក្រៅពីតម្លៃនៃការបង្រៀនរបស់ពួកគេសម្រាប់សិស្សានុសិស្ស
     និងកម្មវិធីសិក្សាផ្នែកវេជ្ជសាស្ត្របញ្ចប់ការសិក្សា
     របាយការណ៍ករណីបានផ្តល់នូវចំណុចចាប់ផ្តើមសម្រាប់អ្នកស្រាវជ្រាវថ្មី ដែលអាចរៀបចំ
     និងលើកទឹកចិត្តពួកគេ ឱ្យស្វែងរកបទពិសោធន៍សរសេរតាមបរិបទបន្ថែមនាពេលអនាគត។
   - វាក៏អាចផ្តល់ឱ្យអ្នកព្យាបាលជាន់ខ្ពស់ (senior clinicians)
     នូវព័ត៌មានអំពីជំងឺរាតត្បាតដែលកំពុងកើតឡើង ឬរោគសញ្ញាដែលមិនស្គាល់ពីមុនមក
     (previously unknown syndromes)។
   - កត្តាខាងក្រៅចំពោះវិធីសាស្ត្រសិក្សានេះ គឺការខ្វះលទ្ធភាពទូទៅ (lack of generalizability)
     និងផលប៉ះពាល់សម្រាប់ការអនុវត្តគ្លីនិក ដែលជាដែនកំណត់ចម្បង (primary limitations)។

7. **ការវិភាគទិន្នន័យរួមគ្នាច្រើន (Meta-analysis)**
   - ការវិភាគទិន្នន័យរួមគ្នាច្រើន (Meta-analysis) គឺជាការរចនាការសិក្សា ជាផ្លូវការ
     បរិមាណវិស័យ
     និងជាអេពីដេមីសាស្ត្រដែលប្រើសម្រាប់វាយតម្លៃជាប្រព័ន្ធនៃការសិក្សាស្រាវជ្រាវពីមុន
     និងទាញការសេចក្តីសន្និដ្ឋានអំពីអត្ថបទឯកសារសិក្សាស្រាវជ្រាវ (the corpus of research)។

- លទ្ធផលនៃការវិភាគទិន្នន័យរួមគ្នាច្រើនអាចផ្តល់នូវការប៉ាន់ប្រមាណច្បាស់លាស់ជាងអំពីឥទ្ធិពលនៃការព្យាបាល ឬកត្តាហានិភ័យនៃជំងឺ ឬលទ្ធផលផ្សេងទៀត ជាងការសិក្សាលក្ខណៈបុគ្គលដែលបានរួមចំណែកដល់ការវិភាគសរុប (aggregated analysis)។
- ការពិនិត្យមើលភាពប្រែប្រួល ឬភាពខុសប្លែកគ្នានៃលទ្ធផលសិក្សា គឺជាលទ្ធផលដ៏សំខាន់មួយទៀត
- អត្ថប្រយោជន៍នៃការវិភាគទិន្នន័យរួមគ្នាច្រើន រួមមានការពិនិត្យបរិមាណវិស័យអំពីអត្ថបទស្រាវជ្រាវទ្រង់ទ្រាយធំ ស្មុគស្មាញញឹកញាប់ និងពេលខ្លះវាហាក់ដូចជាផ្ទុយគ្នា។
- ការស្វែងរកឯកសារសេីប (sensitive literature search) គឺមានសារៈសំខាន់ចំពោះដំណើរការនៃការវិភាគទិន្នន័យរួមគ្នាច្រើន ក៏ដូចជាការបញ្ជាក់អំពីលទ្ធផល និងសម្មតិកម្មដែលត្រូវធ្វើតេស្ត។
- ការខកខានមិនបានកំណត់រកឲ្យឃើញថា ភាគច្រើននៃការសិក្សាដែលមានស្រាប់ គឺអាចនាំឱ្យមានការសន្និដ្ឋានខុស។ ទោះយ៉ាងណាក៏ដោយ មានបច្ចេកទេសដូចជា funnel plots (គ្រោងចីវលោ) សម្រាប់ពិនិត្យទិន្នន័យ ដើម្បីកំណត់លទ្ធភាពនៃការសិក្សាដែលបាត់ (possibility of missing studies)។
- នៅក្នុងផ្នែកវេជ្ជសាស្ត្រផ្អែកលើភស្តុតាង ការវិភាគទិន្នន័យរួមគ្នាច្រើន ដែលធ្វើឡើងដោយម៉ត់ចត់ គឺជាឧបករណ៍ដ៏មានប្រយោជន៍។
- តម្រូវការក្នុងការបញ្ចូលការរកឃើញពីការសិក្សាជាច្រើន ធ្វើឱ្យការវិភាគទិន្នន័យរួមគ្នាច្រើនដែលចង់បាន ហើយការស្រាវជ្រាវជាច្រើនដែលឥឡូវនេះកំពុងត្រូវបានបង្កើតឡើង ធ្វើឱ្យការប្រព្រឹត្តិរបស់វាអាចធ្វើទៅបាន។

សម្រាប់ការរចនាការស្រាវជ្រាវបរិមាណវិស័យ (quantitative research design) គ្រោងជ្រើសរើសសំណាក (sampling frame), ទំហំសំណាក (sample size) និងឥទ្ធិពលស្ថិតិ (statistical power) គួរតែត្រូវបានគណនា និងកែសម្រួលឲ្យបានត្រឹមត្រូវ (justified) នៅក្នុងផ្នែកវិធីសាស្ត្រ។ សម្រាប់នីតិជ្រើសរើសសំណាក (sampling procedures) លក្ខខណ្ឌទាំងនេះគួរតែត្រូវបានប្រើប្រសិនបើសមស្រប៖ សំណាកចៃដន្យ (ប្រសិនបើភាពចៃដន្យគឺសំដៅលើការជ្រើសរើសផ្លូវការ ចៃដន្យ ដែលបុគ្គលម្នាក់ៗដែលមានសិទ្ធិទាំងអស់នឹងមានឱកាសជ្រើសរើសថេរ និងជាធម្មតាស្មើភាពគ្នា) សំណាកផ្អែកលើក្រុមមនុស្ស (population-based sample) សំណាកយោង(referred sample) សំណាកជាប់គ្នា (consecutive sample) សំណាកស្ម័គ្រចិត្ត (volunteer sample) សំណាកងាយស្រួល

(convenience sample)។ ប្រសិនបើការផ្ទៀងផ្ទាត់ត្រូវបានប្រើសម្រាប់ក្រុមប្រៀបធៀប លក្ខណៈដែលត្រូវបានផ្ទៀងផ្ទាត់គួរតែត្រូវបានបញ្ជាក់។

### 4.6.2. វិធីសាស្ត្រគុណវិស័យ

ការស្រាវជ្រាវគុណវិស័យ ត្រូវបានអនុវត្តដើម្បីស្វែងរកកត្តា "ហេតុអ្វី" និង "របៀបណា" នៅក្នុងសំណួរស្រាវជ្រាវរបស់អ្នក។ វាមានលក្ខណៈរុករក និងមិនមែនអំពីការបង្កើតតួលេខទេ។ ផ្ទុយមកវិញ ការស្រាវជ្រាវគុណវិស័យផ្តោតលើហេតុផល ការលើកទឹកចិត្ត អាកប្បកិរិយា និងគំនិតនៅក្នុងសំណួរស្រាវជ្រាវរបស់អ្នក។ វាល្អបំផុតក្នុងការជួយអ្នកឱ្យទទួលបានការយល់ដឹង និងស្វែងយល់ស៊ីជម្រៅទៅក្នុងបញ្ហាជាក់លាក់ណាមួយ។ ប្រភេទនៃទិន្នន័យនេះជាធម្មតាបានមកពីការសន្ទនា ការសម្ភាសន៍ និងការឆ្លើយតបទៅនឹងសំណួរបើក។ ការស្រាវជ្រាវគុណវិស័យគឺដើម្បីប្រមូល និងវិភាគទិន្នន័យដែលមិនមែនជាលេខ (ឧ. អត្ថបទ វីដេអូ ឬអូឌីយ៉ូ) ដើម្បីយល់ពីគំនិត(concepts) យោបល់ (opinions) ឬបទពិសោធន៍។ វាអាចត្រូវបានប្រើដើម្បីប្រមូលការយល់ដឹងស៊ីជម្រៅទៅក្នុងបញ្ហាណាមួយ ឬបង្កើតគំនិតថ្មីណាមួយសម្រាប់ការស្រាវជ្រាវ។

វិធីសាស្ត្រគុណវិស័យអាចរួមមាន៖

1. **ការសម្ភាសស៊ីជម្រៅ** (In-Depth Interview (IDI))
   - ការសម្ភាសន៍គ្មានការគ្រោងទុក ដោយមានសំណួរបើក។
   - មានភាពបត់បែន ដើម្បីឱ្យអ្នកឆ្លើយសំណួរពិភាក្សាអំពីមតិរបស់ពួកគេ។
   - ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII) ដើម្បីស្វែងយល់ពីការយល់ដឹងពីភាគីពាក់ព័ន្ធដែលបានជ្រើសរើស។
   - ជំនាញសម្ភាសន៍ និងសម្របសម្រួលទំនាក់ទំនងរបស់អ្នកស្រាវជ្រាវមានសារៈសំខាន់ណាស់ក្នុងការប្រមូលទិន្នន័យគុណវិស័យល្អ។

2. **ការពិភាក្សាផ្តោតជាក្រុម** (Focus Group Discussion (FGD))
   - ការពិភាក្សា និងការធ្វើអន្តរកម្មពាក់កណ្តាលគ្រោងទុកជាក្រុមស្តីពីការផ្លាស់ប្តូរគំនិត និងយោបល់ក្នុងចំណោមអ្នកចូលរួម។
   - ប្រភេទនៃការសម្ភាសជាក្រុមដែលស្វែងយល់ពីបញ្ហាប្រធានបទ។
   - អ្នកដឹកនាំក្រុម (អ្នកសម្របសម្រួល) នឹងស្វែងរកប្រធានបទជាក់លាក់មួយជាមួយក្រុមដោយសួរសំណួរ ស្តាប់ចម្លើយដោយយកចិត្តទុកដាក់ និងសួរសំណួរប្រដេញដើម្បីតាមដានការឆ្លើយតប។
   - អ្នកកត់ត្រារក្សាកំណត់ត្រា និងកំណត់អត្តសញ្ញាណប្រតិកម្ម និងអន្តរកម្មជាក់លាក់ក្នុងចំណោមអ្នកចូលរួម។

- គួរតែមានអ្នកចូលរួមប្រហែល ៨-១០ នាក់ដែលត្រូវបានជ្រើសរើសនៅក្នុង FGD។ វគ្គនីមួយៗមិនគួរមានរយៈពេលលើសពីមួយម៉ោងកន្លះឡើយ។

3. **ការសង្កេតផ្ទាល់** (Direct Observation)
   - វាត្រូវបានគេស្គាល់ផងដែរថាជាការសិក្សាបែបសង្កេត ការប្រមូលព័ត៌មានវាយតម្លៃ ខណៈពេលដែលអ្នកវាយតម្លៃមើលបុគ្គលគោលដៅ នៅក្នុងបរិយាកាសធម្មតារបស់គាត់ ដោយមិនផ្លាស់ប្តូរបរិយាកាសនោះ។
   - ការសង្កេតផ្ទាល់ត្រូវបានប្រើនៅពេលដែលការប្រមូលទិន្នន័យផ្សេងទៀត (ដូចជាការស្ទង់មតិ ឬកម្រងសំណួរ) មិនមានប្រសិទ្ធភាព។
   - គោលដៅ គឺដើម្បីវាយតម្លៃដំណើរការអាកប្បកិរិយា ព្រឹត្តិការណ៍ ឬស្ថានភាពដែលកំពុងបន្ត ឬនៅពេលដែលមានលទ្ធផលរូបវន្ត ដែលអាចមើលឃើញយ៉ាងងាយស្រួល។
   - ការសង្កេតផ្ទាល់តាមការគ្រោងទុក គឺមានភាពសមស្របបំផុត នៅពេលដែលព័ត៌មានស្តង់ដារត្រូវប្រមូលផ្តុំ និងអាចបណ្តាលឱ្យមានទិន្នន័យបរិមាណវិស័យ (quantitative data)។
   - ការសង្កេតផ្ទាល់ឥតគ្រោងទុក មើលទៅលើការកើតឡើងដោយធម្មជាតិ និងផ្តល់នូវទិន្នន័យគុណវិស័យ។
   - បញ្ហាសំខាន់មួយនៃការសង្កេតផ្ទាល់គឺ "ឥទ្ធិពល Hawthorne" មានន័យថាមនុស្សជាធម្មតាអនុវត្តបានប្រសើរជាងនៅពេលដែលពួកគេត្រូវបានគេសង្កេត។
   - បញ្ហាមួយទៀតគឺ "ភាពលំអៀងរបស់អ្នកសង្កេត" ដែលបង្កឡើងដោយកត្តាផ្ទាល់ខ្លួន ឬវត្ថុបំណងដែលប៉ះពាល់ដល់លទ្ធផលវាយតម្លៃ។

4. **ករណីសិក្សា/ប្រវត្តិជីវិត** (Case Study/Life History)
   - វាគឺជាការសិក្សាស៊ីជម្រៅអំពីបញ្ហាសុខភាពដែលបានសិក្សាតាមរយៈករណីមួយ ឬច្រើនក្នុងការទីតាំងណាមួយ ឬបរិបទណាមួយ (within a setting or a context)។
   - វាក៏ជាការពណ៌នាស៊ីជម្រៅអំពីបទពិសោធន៍របស់មនុស្សនៅលីវ គ្រួសារ ក្រុម សហគមន៍ ឬអង្គការ។
   - ឧទាហរណ៍អំពីករណីសិក្សាគុណវិស័យ គឺជាប្រវត្តិជីវិត ដែលជារឿងរបស់មនុស្សជាក់លាក់ម្នាក់ដែលគាត់អាចជាតំណាងនៃប្រធានបទស្រាវជ្រាវ។
   - ករណីសិក្សាអាចត្រូវបានធ្វើដើម្បីរំលេចបញ្ហាជាក់លាក់មួយ ដោយប្រាប់រឿងរបស់បុគ្គលម្នាក់ ឬក្រុមមួយ។
   - ប្រភពព័ត៌មានជាច្រើនដើម្បីផ្តល់នូវរឿងរ៉ាវករណីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។
   - ទិន្នន័យត្រូវបានប្រមូលតាមរយៈការសង្កេត ការសម្ភាស ប្រវត្តិផ្ទាល់មាត់ និងឯកសារ។

ទោះបីជាការសិក្សាគុណវិស័យអាចសួរសំណួរទូលំទូលាយ មានលក្ខណៈរុករក និងអន្តរទំនាក់ទំនង ដែលមិនតែងតែអាចបញ្ជាក់បានជាមុន ថាជាសម្មតិកម្មធម្មតាក៏ដោយ ក៏វាចាំបាច់ក្នុងការផ្តល់នូវការយល់ឃើញ និងហេតុផលត្រឹមត្រូវ ឬហេតុផលសម្រាប់ការស្រាវជ្រាវដែរ។ ទាំងនេះអាចត្រូវបានបកស្រាយថា ជាបញ្ហាស្រាវជ្រាវទូលំទូលាយដែលត្រូវស៊ើបអង្កេត ជាជាងសម្មតិកម្មដែលបានកំណត់ទុកជាមុន (pre-determined hypotheses)។ តម្លាភាពអំពីក្របខណ្ឌគំនិត និងទស្សនវិស័យដែលបានអនុវត្ត គឺមានសារៈសំខាន់ណាស់ សម្រាប់ការស្រាវជ្រាវវិមាណវិស័យ និងគុណវិស័យ។

អ្នកស្រាវជ្រាវគួរតែពណ៌នាអំពីទីតាំងនៃការសិក្សា ដើម្បីកំណត់ពីលទ្ធភាពនៃការអនុវត្តរបាយការណ៍ចំពោះកាលៈទេសៈផ្សេងទៀត ឧទាហរណ៍ ការថែទាំផ្តោតលើក្រុមមនុស្ស ឬថែទាំបឋម ឬមជ្ឈមណ្ឌលបង្អែក (referral center)។ ការពណ៌នាសង្ខេបអំពីទីតាំងដែលជាកន្លែងស្រាវជ្រាវបានកើតឡើងគឺចាំបាច់ណាស់។ ភាពទន់ខ្សោយទូទៅក្នុងការស្រាវជ្រាវ ជាពិសេសក្នុងការសិក្សាគុណវិស័យ គឺជាទំនោរក្នុងការផ្តល់ជូនតែទិដ្ឋភាពទូទៅថ្នាក់ជាតិ ឬតំបន់នៃករណីដែលមានការជូនដំណឹង និងអត្រាប្រេវ៉ាឡង់ដែលបានប៉ាន់ប្រមាណ ខណៈពេលដែលការមិនយកចិត្តទុកដាក់លើបរិបទសង្គម វប្បធម៌ យេនឌ័រ សេដ្ឋកិច្ច ឬនយោបាយដែលការគ្រប់គ្រងជំងឺរបេងត្រូវបានបង្កប់។

### 4.6.3. វិធីសាស្រ្តចម្រុះ

ដើម្បីឆ្លើយសំណួរស្រាវជ្រាវស្មុគស្មាញ ការស្រាវជ្រាវវិធីសាស្រ្តចម្រុះ រួមបញ្ចូលធាតុផ្សំនៃការស្រាវជ្រាវបរិមាណវិស័យ និងការស្រាវជ្រាវគុណវិស័យ។ ការបញ្ចូលនូវអត្ថប្រយោជន៍នៃវិធីសាស្រ្តស្រាវជ្រាវទាំងបរិមាណ និងគុណវិស័យ វិធីសាស្រ្តចម្រុះអាចឱ្យអ្នកស្រាវជ្រាវទទួលបានរូបភាពពេញលេញជាងការស្រាវជ្រាវបរិមាណវិស័យ ឬគុណវិស័យតែមួយ។ នៅពេលបង្កើតសំណួរស្រាវជ្រាវ អ្នកស្រាវជ្រាវគួរតែព្យាយាមដោះស្រាយដោយផ្ទាល់អំពីរបៀបដែលវិធីសាស្រ្តគុណវិស័យ និងបរិមាណវិស័យនឹងត្រូវបានរួមបញ្ចូលគ្នា។

ការស្រាវជ្រាវវិធីសាស្រ្តចម្រុះ មិនគ្រាន់តែរួមបញ្ចូលការប្រមូលទិន្នន័យទាំងពីរប្រភេទនោះទេ ផ្ទុយទៅវិញ អ្នកស្រាវជ្រាវត្រូវតែពិចារណាយ៉ាងជិតដល់នូវទំនាក់ទំនងរវាងវិធីសាស្រ្តទាំងពីរនេះ ហើយបញ្ចូលការរកឃើញរបស់ពួកគេក្នុងលក្ខណៈស៊ីសង្វាក់គ្នា។ ដោយផ្អែកលើកាលប្បវត្តិ(chronology)នៃការស្រាវជ្រាវគុណវិស័យ និងបរិមាណវិស័យ ការស្រាវជ្រាវចម្រុះមានគោលបំណងស្រាវជ្រាវបីផ្សេងគ្នា៖

1. ការប្រើប្រាស់ការរកឃើញគុណវិស័យដើម្បីបង្កើតឧបករណ៍ស្រាវជ្រាវបរិមាណវិស័យថ្មី៖ ការស្រាវជ្រាវគុណវិស័យត្រូវបានធ្វើឡើងមុនគេ តាមដោយការស្រាវជ្រាវវិមាណវិស័យ។

2. ការកំណត់ថា តើការរកឃើញបរិមាណវិស័យណាមួយ ត្រូវការការពន្យល់បន្ថែម។ ការស្រាវជ្រាវបរិមាណវិស័យមុនការស្រាវជ្រាវគុណវិស័យ។
3. ការប្រៀបធៀបភាពស្រដៀងគ្នា និងភាពខុសគ្នារវាងការរកឃើញគុណវិស័យ និងបរិមាណវិស័យ៖ វិធីសាស្ត្រស្រាវជ្រាវទាំងពីរត្រូវបានធ្វើឡើងស្របគ្នាសម្រាប់ការប្រៀបធៀប។

អ្នកស្រាវជ្រាវនៃវិធីសាស្ត្រចម្រុះ ត្រូវតែបង្កើតករណីសង្ខេប ប៉ុន្តែគួរឱ្យទាក់ទាញ សម្រាប់របៀបដែលវិធីសាស្ត្រទាំងពីរផ្តល់ព័ត៌មានដល់ការសិក្សាឲ្យគ្នាទៅវិញទៅមក។ ការស្រាវជ្រាវវិធីសាស្ត្រចម្រុះច្រើនតែទាមទារការពិពណ៌នាវែងឆ្ងាយអំពីនីតិវិធីសិក្សា ដោយផ្តល់ចន្លោះតិចតួច (little space) សម្រាប់ការពិភាក្សា និងការសន្និដ្ឋាន។ ភាពទន់ខ្សោយទូទៅមួយនៅក្នុងការស្រាវជ្រាវវិធីសាស្ត្រចម្រុះ គឺវិធីសាស្ត្រមួយត្រូវបានពណ៌នាយ៉ាងទូលំទូលាយពេក និងមួយទៀតត្រូវបានធ្វើឡើងសើៗ (superficially developed)។ ប្រសិនបើវិធីសាស្ត្រទាំងពីរត្រូវបានប្រើ នោះវាចាំបាច់ណាស់ក្នុងការពណ៌នាអំពីទំនាក់ទំនងរវាងទិន្នន័យទាំងពីរប្រភេទដែលប្រមូលបាន។

## 4.7. វិធីសាស្ត្រជ្រើសរើសសំណាកស្រាវជ្រាវ

ការជ្រើសរើសសំណាក គឺជាបច្ចេកទេសមួយសម្រាប់ជ្រើសរើសបុគ្គលជាក់លាក់ ឬផ្នែកតូចមួយនៃក្រុមមនុស្ស ដើម្បីធ្វើការសន្និដ្ឋានអំពីក្រុមមនុស្សទាំងមូល និងប៉ាន់ស្មានចារឹកលក្ខណៈរបស់វា។ ការអនុវត្តបច្ចេកទេសជ្រើសរើសសំណាកផ្សេងៗក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវមិនចាំបាច់សិក្សាសហគមន៍ពេញលេញដើម្បីប្រមូលព័ត៌មានដែលមានប្រយោជន៍នោះទេ។ វាក៏ជាវិធីសាស្ត្រដែលងាយស្រួល និងសន្សំសំចៃពេលវេលាផងដែរ ដែលជាមូលដ្ឋាននៃការរចនាការស្រាវជ្រាវ (any research design)។ ការរចនាការស្រាវជ្រាវអាចប្រើបច្ចេកទេសជ្រើសរើសសំណាកប្រូបាប៊ីលីតេ ឬមិនប្រូបាប៊ីលីតេ អាស្រ័យលើប្រូបាប៊ីលីតេនៃការជ្រើសរើសដែលយកមកពិចារណា។

### 4.7.1. វិធីសាស្ត្រជ្រើសរើសសំណាកប្រូបាប៊ីលីតេ

វិធីសាស្ត្រជ្រើសរើសសំណាកប្រូបាប៊ីលីតេចំនួនបួន ត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយនៅក្នុងការស្រាវជ្រាវ៖

1. **ការជ្រើសរើសសំណាកចៃដន្យសាមញ្ញ** (Simple random sampling)៖
   - មនុស្សគ្រប់រូបក្នុងក្រុមមនុស្ស មានប្រូបាប៊ីលីតេស្មើគ្នា ក្នុងការជ្រើសរើសនៅក្នុងការជ្រើសរើសសំណាកចៃដន្យសាមញ្ញ។
   - ក្រុមមនុស្សទាំងមូលគួរតែត្រូវបានរួមបញ្ចូលនៅក្នុងគ្រោងជ្រើសរើសសំណាករបស់អ្នក។
   - អ្នកអាចប្រើប្រាស់ឧបករណ៍ដូចជាម៉ាស៊ីនបង្កើតលេខដោយចៃដន្យ ឬវិធីសាស្ត្រផ្សេងទៀតដែលគ្រាន់តែពឹងផ្អែកលើឱកាសដើម្បីអនុវត្តការជ្រើសរើសសំណាកប្រភេទនេះ។

2. **ការជ្រើសរើសសំណាកជាចង្កោម** (Cluster sampling)

- ការជ្រើសរើសសំណាកជាចង្កោម ក៏ពាក់ព័ន្ធនឹងការបែងចែកក្រុមមនុស្សទៅជាក្រុមរងផងដែរ ប៉ុន្តែក្រុមរងនីមួយៗ គួរតែមានលក្ខណៈស្រដៀងគ្នាទៅនឹងសំណាកទាំងមូល។
- ជំនួសឱ្យការជ្រើសរើសសំណាកពីបុគ្គលម្នាក់ពីក្រុមរង (subgroup) នីមួយៗ អ្នកជ្រើសរើសក្រុមរងទាំងមូលដោយចៃដន្យ។
- ប្រសិនបើវាអាចធ្វើទៅបាន អ្នកអាចរួមបញ្ចូលបុគ្គលម្នាក់ៗពីចង្កោមដែលត្រូវបានជ្រើសរើសសំណាកនីមួយៗ។
- ប្រសិនបើចង្កោមមានទំហំធំ អ្នកអាចជ្រើសរើសសំណាកពីបុគ្គលពីក្នុងចង្កោមនីមួយៗដោយប្រើបច្ចេកទេសមួយដែលបានពណ៌នាខាងលើ។ ចំណុចនេះត្រូវបានគេស្គាល់ថា ការជ្រើសរើសសំណាកពហុដំណាក់កាល (multi-stage sampling)។
- ទោះបីជាយុទ្ធសាស្ត្រនេះមានប្រសិទ្ធភាពសម្រាប់ចាត់ចែងក្រុមមនុស្សធំ និងបែកខ្ញែកក៏ដោយ ក៏មានឱកាសខ្ពស់នៃការកើតមានកំហុសនៅក្នុងសំណាកដែរ ដោយសារលទ្ធភាពនៃភាពខុសគ្នាខ្លាំងរវាងចង្កោម។ វាពិតជាលំបាកណាស់ក្នុងការធានាថាចង្កោមដែលបានយកសំណាកបានត្រឹមត្រូវឆ្លុះបញ្ចាំងពីក្រុមមនុស្សទាំងមូល។

3. **ការជ្រើសរើសសំណាកជាប្រព័ន្ធ** (Systematic sampling)៖

- មនុស្សគ្រប់រូបនៅក្នុងក្រុមមនុស្សត្រូវបានផ្តល់លេខមួយ ប៉ុន្តែជំនួសឱ្យការផ្តល់លេខដោយចៃដន្យ មនុស្សត្រូវបានជ្រើសរើសនៅចន្លោះពេលដែលបានកំណត់ទុកជាមុន។
- សំណាកចៃដន្យសាមញ្ញ (Simple random sample) និងការជ្រើសរើសសំណាកជាប្រព័ន្ធ (systematic sampling) គឺអាចប្រៀបធៀបបាន ប៉ុន្តែការជ្រើសរើសសំណាកជាប្រព័ន្ធមានលក្ខណៈងាយស្រួលអនុវត្ត។

4. **វិធីជ្រើសរើសសំណាកក្រុមសមមូល** (Stratified sampling)៖

- វិធីជ្រើសរើសសំណាកក្រុមសមមូល (Stratified sampling) ត្រូវបានប្រើដើម្បីបែងចែកក្រុមមនុស្សទៅជាក្រុមរងដែលអាចមានភាពខុសគ្នាខ្លាំង។
- វាអនុញ្ញាតឱ្យអ្នកទាញយកការសន្និដ្ឋានច្បាស់លាស់បន្ថែមទៀត ដោយធានាថាក្រុមរងទាំងអស់ត្រូវបានតំណាងយ៉ាងគ្រប់គ្រាន់នៅក្នុងសំណាក។
- នៅពេលប្រើវិធីជ្រើសរើសសំណាកនេះ អ្នកអាចបែងចែកក្រុមមនុស្សទៅជាក្រុមរង (ហៅថា strata) ដោយផ្អែកលើលក្ខណៈដែលពាក់ព័ន្ធ (ឧ. អត្តសញ្ញាណយេនឌ័រ ក្រុមអាយុ ប្រាក់ចំណូល តួនាទីការងារ)។
- អ្នកគណនាចំនួនមនុស្សដែលគួរត្រូវបានយកសំណាកចេញពីក្រុមរងនីមួយៗ ដោយផ្អែកលើសមាមាត្រនៃក្រុមមនុស្សសរុប។

- បន្ទាប់មក អ្នកជ្រើសរើសសំណាកពីក្រុមរងនីមួយៗ ដោយប្រើវិធីជ្រើសរើសសំណាកចៃដន្យ ឬជាប្រព័ន្ធ។

## 4.7.2. វិធីសាស្ត្រជ្រើសរើសសំណាកមិនមែនប្រូបាប៊ីលីតេ

វិធីសាស្ត្រជ្រើសរើសសំណាកប្រូបាប៊ីលីតេចំនួនបួនត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងការស្រាវជ្រាវ៖

1. **វិធីជ្រើសរើសសំណាកងាយ** (Convenient sampling)
    - វិធីជ្រើសរើសសំណាកងាយ (convenience sample) មានមនុស្សដែលអ្នកស្រាវជ្រាវអាចចូលជួបបានយ៉ាងងាយស្រួល។
    - នេះគឺជាវិធីសាមញ្ញ និងមានតំលៃថោកក្នុងការប្រមូលទិន្នន័យបឋម ប៉ុន្តែមិនមានវិធីដើម្បីដឹងថាតើសំណាកនោះជាតំណាងនៃក្រុមមនុស្សទេ ដូច្នេះលទ្ធផលគឺមិនអាចបង្ហាញជាទូទៅបានទេ។
    - វិធីជ្រើសរើសសំណាកងាយ (convenience sample) គឺងាយរងគ្រោះដោយការលំអៀងតាមការជ្រើសរើសសំណាក និងការជ្រើសរើស។
    - សំណាកឆ្លើយតបដោយស្ម័គ្រចិត្ត (voluntary response sample) ដូចជាសំណាកងាយត្រូវបានលើកទឹកចិត្តជាចម្បងដោយភាពងាយស្រួលចូលប្រើ។
    - មនុស្សស្ម័គ្រចិត្តដោយខ្លួនឯងជាជាងអ្នកស្រាវជ្រាវជ្រើសរើស និងទាក់ទងពួកគេ (ឧ. ដោយការឆ្លើយតបទៅនឹងការស្ទង់មតិជាសាធារណៈតាមអ៊ីនធឺណិត)។
2. **វិធីជ្រើសរើសសំណាកតាមបំណង** (Purposive sampling)
    - ប្រភេទនៃវិធីជ្រើសរើសសំណាកនេះ ត្រូវបានគេស្គាល់ថាជាវិធីជ្រើសរើសសំណាកវិនិច្ឆ័យ (judgment sampling) ធ្វើឱ្យអ្នកស្រាវជ្រាវប្រើប្រាស់ជំនាញរបស់ពួកគេដើម្បីជ្រើសរើសសំណាកដែលមានប្រយោជន៍បំផុត ចំពោះវត្ថុបំណងនៃការស្រាវជ្រាវ។
    - វាត្រូវបានគេប្រើជាញឹកញាប់នៅក្នុងការស្រាវជ្រាវគុណវិស័យ ដែលអ្នកស្រាវជ្រាវចង់ទទួលបានចំណេះដឹងលម្អិតអំពីបាតុភូតជាក់លាក់មួយ ជាជាងបង្កើតនូវសេចក្តីសន្និដ្ឋានស្ថិតិ (statistical inferences) ឬនៅពេលដែលក្រុមមនុស្សមានចំនួនតិច និងជាក់លាក់។
    - សំណាកតាមគោលបំណងដែលមានប្រសិទ្ធភាព (An effective purposive sample) ត្រូវតែមានលក្ខណៈវិនិច្ឆ័យបរិយាបន្ន (inclusion criteria) និងហេតុផលច្បាស់លាស់។
    - តែងតែពណ៌នាអំពីលក្ខណៈវិនិច្ឆ័យបរិយាបន្ន (inclusion criteria) និងមិនបរិយាបន្នរបស់អ្នក(exclusion criteria) និងត្រូវចងចាំអំពីភាពលំអៀងនៃការសង្កេតនៅក្នុងទឡ្ហីករណ៍របស់អ្នក។
3. **វិធីជ្រើសរើសសំណាកតាមការប្រាប់តគ្នា** (Snowball sampling)៖

- វិធីជ្រើសរើសសំណាកតាមការប្រាប់តគ្នា (Snowball sampling) អាចត្រូវបានប្រើដើម្បីជ្រើសរើសអ្នកចូលរួមតាមរយៈអ្នកចូលរួមផ្សេងទៀត ប្រសិនបើពិបាកស្វែងរកក្រុមមនុស្ស។
- ចំនួនមនុស្សដែលអ្នកអាចទាក់ទង "ប្រាប់តគ្នា" នៅពេលអ្នកធ្វើការទំនាក់ទំនងកាន់តែច្រើន។
- គុណវិបត្តិគឺថាអ្នកមិនមានវិធីដឹងថាតើសំណាករបស់អ្នកគឺបែបណាដោយសារការពឹងផ្អែកឱ្យអ្នកចូលរួមជ្រើសរើសអ្នកផ្សេងទៀត។
- នេះអាចបណ្តាលឱ្យមានភាពលំអៀងនៃវិធីជ្រើសរើសសំណាក (sampling bias)។

4. **វិធីជ្រើសរើសសំណាកតាមកូតា (Quota sampling)**
    - វិធីជ្រើសរើសសំណាកតាមកូតា (Quota sampling) បែងចែកក្រុមមនុស្សទៅជាក្រុមរង ដោយផ្អែកលើលក្ខណៈដូចជាអាយុ ឬទីតាំង និងបង្កើតគោលដៅសម្រាប់ចំនួនអ្នកឆ្លើយតបដែលត្រូវការពីក្រុមរងនីមួយៗ។
    - ភាពខុសគ្នាចំបងរវាងវិធីជ្រើសរើសសំណាកតាមកូតា (quota sampling) និងវិធីជ្រើសរើសសំណាកចៃដន្យក្រុមសមមូល (stratified random sampling) គឺថាបច្ចេកទេសជ្រើសរើសសំណាកចៃដន្យ (random sampling technique) មិនត្រូវបានប្រើក្នុងវិធីជ្រើសរើសសំណាកតាមកូតា (Quota sampling)ទេ។

## 4.8. ឧបករណ៍ប្រមូលទិន្នន័យ

### 4.8.1. ឧបករណ៍ប្រមូលទិន្នន័យបរិមាណវិស័យ

មុននឹងប្រើឧបករណ៍ប្រមូលទិន្នន័យ អ្នកស្រាវជ្រាវគួរតែសញ្ជឹងគិតអំពីលក្ខណៈនៃការរចនាការសិក្សា (study design) ដូចខាងក្រោម៖

- ប្រភេទអថេរ (Variable type)៖ គិតអំពីប្រភេទព័ត៌មានដែលអ្នកចង់ប្រមូល ឯកទេសស្រាវជ្រាវរបស់អ្នក និងគោលដៅរួមនៃការសិក្សា។
- ការរចនាការសិក្សា (Study design)៖ ជ្រើសរើសវិធីសាស្រ្តដែលអ្នកនឹងប្រើដើម្បីប្រមូលទិន្នន័យនេះ។
- វិធីសាស្រ្តប្រមូលទិន្នន័យ៖ សម្រេចចិត្តលើបច្ចេកទេស និងឧបករណ៍ដែលអ្នកចង់ប្រមូលទិន្នន័យ។
- គ្រោងវិធីជ្រើសរើសសំណាក (Sampling frame)៖ ដំបូងសម្រេចចិត្តជ្រើសរើសកន្លែងដែលអ្នកចង់ប្រមូលទិន្នន័យ។ បន្ទាប់មក កំណត់ក្រុមមនុស្សដែលត្រូវយកសំណាក។ ដូចគ្នានេះដែរ ត្រូវស្វែងយល់ថាតើផ្នែកណានៃក្រុមមនុស្សដែលនឹងត្រូវបានរួមបញ្ចូលនៅក្នុងការស៊ើបអង្កេតរបស់អ្នក។
- ទំហំសំណាក (Sample size)៖ ពិចារណាថាតើមនុស្សចំនួនប៉ុន្មានដែលអ្នកចង់បញ្ចូលក្នុងការសិក្សារបស់អ្នក
- វិធីជ្រើសរើសសំណាក (Sampling method)៖ ពិចារណាពីរបៀបដែលអ្នកនឹងជ្រើសរើសសំណាក។

រាល់ឧបករណ៍ប្រមូលទិន្នន័យត្រូវបញ្ជាក់សុពលភាពមុនពេលប្រមូលទិន្នន័យ។ ការបណ្តុះបណ្តាលយ៉ាងទូលំទូលាយសម្រាប់ក្រុមអ្នកប្រមូលទិន្នន័យរបស់អ្នក និងតាមរយៈការសាកល្បង (pilot) ដ៏ហ្មត់ចត់ គឺជាជំហានដ៏ល្អបំផុតដើម្បីចាប់ផ្តើម ហើយពួកគេគឺជាធាតុផ្សំដ៏សំខាន់នៅក្នុងរាល់ការស្ទង់មតិប្រកបដោយប្រសិទ្ធភាព។ ទោះយ៉ាងណាក៏ដោយ ពួកគេនឹងមិនលុបបំបាត់ទាំងស្រុងនូវភាពមិនត្រឹមត្រូវនៃទិន្នន័យនោះទេ។ ការផ្ទៀងផ្ទាត់ទិន្នន័យអាចជួយអ្នកកាត់បន្ថយកំហុសបានកាន់តែច្រើន។ ដំណោះស្រាយការប្រមូលទិន្នន័យឌីជីថលផ្តល់ជូននូវប្រភេទសំណួរជាច្រើន និងយុទ្ធសាស្ត្របច្ចេកទេសដើម្បីជួយអ្នកក្នុងការបញ្ចូលសុពលភាពប្រកបដោយប្រសិទ្ធភាពក្នុងការស្ទង់មតិរបស់អ្នក និងប្រមូលទិន្នន័យដែលគ្មានកំហុស។

វិធានការបញ្ជាក់សុពលភាពជាច្រើនអាចកែលម្អឧបករណ៍ប្រមូលទិន្នន័យតាមរយៈការសម្ភាសសាកល្បង៖

- ធ្វើឱ្យសំណួរសំខាន់បំផុតរបស់អ្នកក្លាយជាកាតព្វកិច្ច។
- សាកល្បងសំណួរពហុជ្រើសរើស (multiple-choice questions)៖ ដែនកំណត់បិតិវន្ត ឬឋាមវន្ត (dynamic or static limits) លើចំនួននៃការជ្រើសរើសដែលនរណាម្នាក់អាចជ្រើសរើសជម្រើសចៃដន្យនិងការត្រួតពិនិត្យសមហេតុផល លើជម្រើសពិសេសដូចជា "ទាំងអស់ខាងលើ "
- កំណត់តម្លៃអតិបរមា និងអប្បបរមាសម្រាប់សំណួរជាលេខ
- បន្ថែមឡូជីក (logic) សម្រាប់ "គ្មានខាងលើ" (None of the above) និង "ទាំងអស់ខាងលើ"
- កំណត់ចំនួនខ្ទង់ ឬតួអក្សរនៅក្នុងសំណួរ
- កែតម្រូវការស្ទង់មតិតាមបំណង សម្រាប់អ្នកឆ្លើយសំណួរប្រភេទផ្សេងៗគ្នា ដោយប្រើ "រំលងឡូជីក" (skip logic)

សំណួរស្រាវជ្រាវ ឬកម្រងសំណួរ រួមជាមួយនឹងទម្រង់នៃការយល់ព្រម គួរតែត្រូវបានភ្ជាប់មកជាមួយនៅក្នុងផ្នែកឧបសម្ព័ន្ធ។

### 4.8.2. ឧបករណ៍ប្រមូលទិន្នន័យគុណវិស័យ

ឧបករណ៍ប្រមូលទិន្នន័យគុណវិស័យគួរតែបង្ហាញដោយមានការណែនាំអំពីការសម្ភាសជាមុនសិនដើម្បី៖

- កំណត់ប្រធានបទសម្ភាសន៍ និងសំណួរ
- សម្រេចលើកម្រិតលម្អិត
- ពង្រាងសំណួរ
- រៀបសំណួរតាមលំដាប់លំដោយ
- រាយបញ្ជីការសួរប្រដេញ (probes) និងការជម្រុញ (prompts)
- តេស្តសាកល្បងសេចក្តីណែនាំ

ការសួរប្រដេញ (Probing) គឺជាបច្ចេកទេសដែលប្រើដើម្បីជំរុញអ្នកឆ្លើយតបឱ្យផលិតព័ត៌មានបន្ថែម ដោយមិនចាំបាច់បញ្ចូលខ្លួនអ្នកទៅក្នុងអន្តរកម្មច្រើន។ ឧទាហរណ៍អំពីការសួរប្រដេញ (Probing) ត្រូវបានរាយដូចខាងក្រោម៖

- តើអ្នកអាចពន្យល់ចំណុចនោះបន្តិចទៀតបានទេ?
- តើអ្នកអាចឱ្យឧទាហរណ៍មួយអំពីអ្វីដែលអ្នកចង់មានន័យបានទេ?
- តើអ្នកអាចនិយាយបន្ថែមទៀតបានទេ?
- សូមពណ៌នាអំពីអ្វីដែលអ្នកចង់មានន័យ។
- តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះ ដែលធ្វើឲ្យអ្នកមានអារម្មណ៍បែបនេះ?

អំឡុងពេលប្រមូលទិន្នន័យគុណវិស័យ ទម្រង់ជាច្រើននៃកំណត់ត្រាត្រូវបានរក្សាទុកយ៉ាងប្រុងប្រយ័ត្ន រួមមាន៖

- កម្រងសំណួរពាក់កណ្តាលគ្រោងទុក (Semi-structured questionnaires) នៅក្នុង IDI
- កត់ត្រាក្នុង IDI, FGD, និងករណីសិក្សា (Case Study)
- បញ្ជីត្រួតពិនិត្យការសង្កេត (Observation checklist) និងបញ្ជីសារពើភណ្ឌនៅក្នុងការសង្កេតផ្ទាល់
- ការរក្សាទុកកំណត់ហេតុប្រចាំថ្ងៃក្នុងករណីសិក្សា (Case Study)
- ការថតសំឡេងឌីជីថលនៅក្នុង IDI, FGD និងករណីសិក្សា (Case Study)
- ការថតវីដេអូក្នុង FGD ការសង្កេតផ្ទាល់ និងករណីសិក្សា (Case Study)

សំណួរស្រាវជ្រាវ និងការណែនាំអំពីការសម្ភាសរួមជាមួយនឹងទម្រង់ការយល់ព្រម គួរតែភ្ជាប់មកជាមួយនៅផ្នែកឧបសម្ព័ន្ធ។

## 4.9. ផែនការប្រមូលទិន្នន័យ

អ្នកស្រាវជ្រាវគួរតែកំណត់ផែនការប្រមូលទិន្នន័យ រួមទាំងការកំណត់ ការជ្រើសរើស និងការបណ្តុះបណ្តាលក្រុមប្រមូលទិន្នន័យ ពេលវេលាប្រមូលទិន្នន័យ ភាពមានសិទ្ធិរបស់អ្នកចូលរួម ការយល់ព្រម ការលើកទឹកចិត្តសម្រាប់អ្នកចូលរួម ឧបករណ៍សិក្សា (ឧ. កម្រងសំណួរ) និងគ្រោងពេលវេលាគម្រោង។

លក្ខខណ្ឌចូលរួម និងលក្ខណៈសង្គមប្រជាសាស្ត្រសំខាន់ៗរបស់អ្នកជំងឺ (ឬអ្នកចូលរួមក្នុងការសិក្សាផ្សេងទៀត) គួរតែត្រូវបានពណ៌នាលម្អិតដូចជា៖ (ចំនួនអ្នកចូលរួមដែលមានសិទ្ធិ របៀបដែលពួកគេត្រូវបានជ្រើសរើស និងចំនួនដែលបានទាក់ទង (number approached) ប៉ុន្តែអ្នកដែលបដិសេធ ឬត្រូវបានដកចេញ)។ ការជ្រើសរើសបុគ្គលិក ប្រវត្តិ/បទពិសោធន៍ និងផែនការបណ្តុះបណ្តាលសម្រាប់អ្នកប្រមូលទិន្នន័យ គួរតែត្រូវបានកំណត់នៅក្នុងផ្នែកនៃពិធីសារស្រាវជ្រាវនេះ(research protocol)។

អ្នកស្រាវជ្រាវគួរតែបង្កើតនីតិវិធីប្រមូលទិន្នន័យតាមស្តង់ដារ ដើម្បីប្រកាន់ខ្ជាប់នូវលក្ខខណ្ឌតម្រូវផ្នែកក្រមសីលធម៌ស្រាវជ្រាវ។ ពេលវេលាសិក្សាគួរតែត្រូវបានបង្ហាញយ៉ាងច្បាស់នៅចុងបញ្ចប់នៃផ្នែកនេះ។

## 4.10. ផែនការគ្រប់គ្រងទិន្នន័យ

សមាសធាតុសំខាន់មួយនៃការស្រាវជ្រាវប្រកបដោយការទទួលខុសត្រូវ គឺការគ្រប់គ្រងទិន្នន័យ។ អ្នកស្រាវជ្រាវសុខភាពទាំងអស់ទទួលបានប្រធានបទពហុវិមាត្រ (multidimensional topic) ដ៏សំខាន់នេះ ដែលជានាឲ្យមានការពិចារណា និងមានកិច្ចខិតខំប្រឹងប្រែងជាពិសេស។ អ្នកស្រាវជ្រាវ គួរតែដឹងពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងទិន្នន័យ ដើម្បីផ្តល់នូវការគ្រប់គ្រងពេញលេញ និងត្រឹមត្រូវ។ ពួកគេក៏គួរធ្វើឱ្យប្រាកដថាសមាជិកគ្រប់រូបនៃក្រុមគម្រោងស្រាវជ្រាវ ចូលរួមនៅក្នុងការអភិវឌ្ឍ ការអនុវត្ត និងការថែរក្សាគោលនយោបាយ និងនីតិវិធីគ្រប់គ្រងទិន្នន័យផងដែរ។ ដូច្នេះ ផែនការគ្រប់គ្រងទិន្នន័យលម្អិត គួរត្រូវបានព្រាងនៅក្នុងពិធីសារស្រាវជ្រាវនេះ។

ប្រព័ន្ធមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ការគ្រប់គ្រងទិន្នន័យ គួរតែរួមបញ្ចូលប្រព័ន្ធដែលមានលក្ខណៈបន្តបន្ទាប់ (continuous system) សម្រាប់ការវាយតម្លៃយ៉ាងម៉ត់ចត់នូវធាតុផ្សំដែលមានប្រសិទ្ធភាព ឬកង្វះខាត នៅក្នុងពិធីសារគម្រោង ឬដំណើរការប្រមូលទិន្នន័យរបស់ក្រុមអ្នកស្រាវជ្រាវ។ នៅពេលដែលទិន្នន័យស្រាវជ្រាវត្រូវបានប្រមូល កំណត់ត្រាទាំងអស់គួរតែបរិយាយពីស្ថានភាពនៃគម្រោងដោយសមស្រប និងដោះស្រាយបញ្ហារួមទាំង អ្វី របៀបណា និងហេតុអ្វី ដែលទិន្នន័យត្រូវបានទទួល ឬផ្លាស់ប្តូរ។ កំណត់ត្រាត្រូវតែស្ថិតស្ថេរ អាចចូលប្រើបាន និងមានសុវត្ថិភាពប្រឆាំងនឹងការក្លែងបន្លំ ឬការប្រឌិត។ ដើម្បីធានានូវភាពត្រឹមត្រូវនៃទិន្នន័យ ការរក្សាកំណត់ត្រាហ្មត់ចត់ គឺចាំបាច់ណាស់ដែលត្រូវបានពណ៌នានៅក្នុងផែនការនេះ។ ការថែរក្សាទាំងក្រដាស និងកំណត់ត្រាអេឡិចត្រូនិក គួរតែត្រូវបានរៀបចំផែនការ និងការពារឱ្យបានល្អ។

ចាំបាច់ត្រូវគូសបញ្ជាក់ពីនីតិវិធី ដើម្បីការពារនូវព័ត៌មានទាំងអស់នៅក្នុងគម្រោង។ គម្រោងត្រូវតែរក្សាទុកទិន្នន័យឆៅទាំងអស់ដែលប្រមូលបាន ប៉ុន្តែវាក៏ត្រូវរក្សាទុកនូវស្ថិតិ និងការវិភាគសំខាន់ៗពីទិន្នន័យទាំងនេះ ក៏ដូចជាកំណត់ចំណាំ ឬការសង្កេតណាមួយ។ លើសពីនេះទៀត នៅពេលប្រើប្រាស់សំណាកជីវសាស្ត្រសម្រាប់ការសិក្សា នីតិវិធីលម្អិតគួរតែត្រូវបានធ្វើឡើងដើម្បីរក្សាពួកវារហូតដល់គុណភាពរបស់វាធ្លាក់ចុះ (quality deteriorates)។ ទិន្នន័យគម្រោងគួរតែត្រូវបានធានាសុវត្ថិភាពពីការខូចខាតផ្នែករូបវន្ត (physical harm) ក៏ដូចជាពីការបំភ្លៃ ការបាត់បង់ ឬការលួច ដើម្បីរក្សាភាពត្រឹមត្រូវនៃទិន្នន័យដែលបានរក្សាទុក។ នៅក្នុងផែនការនេះ យុទ្ធសាស្ត្រផ្ទុកទិន្នន័យរបស់គម្រោងគួរតែរួមបញ្ចូលការការពារទិន្នន័យ។ ព័ត៌មានលម្អិតបន្ថែមនៅក្នុងការគ្រប់គ្រងទិន្នន័យ ក៏ត្រូវបានបរិយាយនៅក្នុងផ្នែកទី ៦ ការគ្រប់គ្រងទិន្នន័យស្រាវជ្រាវផងដែរ (Section 6. Research Data Management.)។

## 4.11. ផែនការវិភាគទិន្នន័យ

ផែនការវិភាគទិន្នន័យគួរតែផ្តល់នូវការពណ៌នាលម្អិតអំពីការជាប់ទាក់ទង ឬឥទ្ធិពលបុព្វហេតុ (causal effect)ដែលត្រូវប៉ាន់ប្រមាណ និងហេតុផលសម្រាប់ជម្រើសនេះ និងពណ៌នាអំពីវិធីសាស្ត្រដែលបានកំណត់ជាមុន(pre-specified methods) អំពីការវិភាគដើម្បីទាញការសន្និដ្ឋានអំពីការព្យាបាល ឬឥទ្ធិពលនៃការប៉ះពាល់(exposure) ឬការជាប់ទាក់ទង (association) និងផែនការដើម្បីគ្រប់គ្រងរាល់ការសន្និដ្ឋានទាំងឡាយ ដូចដែលបានពិភាក្សាពីមុននៅក្នុងគោលការណ៍ណែនាំទាំងនេះ។

### 4.11.1. ផែនការវិភាគទិន្នន័យបរិមាណវិស័យ

អ្នកស្រាវជ្រាវគួរតែពណ៌នាដោយសង្ខេបអំពីការធ្វើតេស្តស្ថិតិ (statistical tests) ដែលនឹងត្រូវបានប្រើសម្រាប់ការវិភាគ។ បញ្ជាក់កម្រិតសំខាន់ណាមួយជាអាទិភាព និងថាតើការធ្វើតេស្តសម្មតិកម្មមាន ១- ឬ ១ ផ្នែក។ ក៏ត្រូវរួមបញ្ចូលផងដែរនូវកម្មវិធីស្ថិតិ (statistical software) ដែលប្រើសម្រាប់ធ្វើការវិភាគ រួមទាំងកំណែ និងអ្នកផលិត (manufacturer) រួមជាមួយនឹងរាល់កញ្ចប់បន្ថែម (ដូចជា SPSS, STATA ឬ R)។

មិនចាំបាច់ផ្តល់ការពណ៌នាលម្អិតអំពីវិធីសាស្ត្រដែលប្រើដើម្បីបង្កើតស្ថិតិសង្ខេបនោះទេ ប៉ុន្តែការធ្វើតេស្តគួរតែត្រូវបានកត់សម្គាល់ដោយសង្ខេបនៅក្នុងផ្នែកនេះ (ឧទាហរណ៍ ការធ្វើតេស្ត Chi-square, ANOVA ឬ Fisher exact test)។ នៅក្នុងការវិភាគតិតថយក្រោយ (regression analysis) វាគួរតែមានភាពច្បាស់លាស់ដើម្បីកំណត់ម៉ូដែលតិតថយក្រោយ (regression models) ដែលមានអថេរ "ឯករាជ្យ" ច្រើនជាងមួយជាពហុអថេរ(multivariable) ប៉ុន្តែម៉ូដែលតិតថយក្រោយ (regression models) ដែលមានអថេរ "អាស្រ័យ" ច្រើនជាងមួយ ជាពហុអថេរ (multivariate)។

### 4.11.2. ផែនការវិភាគទិន្នន័យគុណវិស័យ

ដោយសារការស្រាវជ្រាវគុណវិស័យគឺជាប្រធានបទ ការវិភាគគុណវិស័យក៏ជាការបកស្រាយ និងក៏ជាប្រធានបទផងដែរ។ អ្នកស្រាវជ្រាវបានរួមចំណែកបកស្រាយ និងអត្ថន័យផ្ទាល់ខ្លួនរបស់ពួកគេដល់ការវិភាគនេះ។ ក្របខណ្ឌគោលគំនិតគួរតែត្រូវបានបង្ហាញនៅដើមដំបូងនៃផែនការវិភាគទិន្នន័យគុណវិស័យ។ ក្របខណ្ឌគោលគំនិតរួមមាន (ជាផ្នែក ឬទាំងមូល) ទ្រឹស្តីផ្លូវការមួយ ឬច្រើន ក៏ដូចជាគំនិតផ្សេងទៀត និងការរកឃើញជាក់ស្តែងពីឯកសារ (literature)។ វាអាចបង្ហាញពីទំនាក់ទំនងរវាងគោលគំនិតទាំងនោះ និងភាពពាក់ព័ន្ធរបស់ពួកគេទៅនឹងការសិក្សាស្រាវជ្រាវ។

វាជាការចាំបាច់សម្រាប់អ្នកស្រាវជ្រាវ ក្នុងការផ្តល់នូវការពណ៌នាយ៉ាងម៉ត់ចត់អំពីវិធីសាស្ត្ររបស់ពួកគេ ក្នុងការដំណើរការទិន្នន័យគុណវិស័យ៖

- វិធីសាស្ត្រកាត់ និងតម្រៀបដើម្បីទាញយកសម្រង់ពាក្យសម្ដីដែលពាក់ព័ន្ធសម្រាប់ប្រធានបទជាក់លាក់មួយ។ លើសពីនេះ វាស្វែងយល់ពីបច្ចេកទេសនៃការតម្រៀបគរគ្នា ដែលពាក់ព័ន្ធនឹងការក្រសោប និងការសាប់ ដើម្បីកំណត់ប្រធានបទរង (sub-themes) នៅក្នុងសម្រង់ពាក្យសម្ដីដែលបានស្រង់ចេញ។
- ការប្រើប្រាស់បញ្ជីពាក្យ និងពាក្យគន្លឹះក្នុងបរិបទជាមធ្យោបាយនៃការសង្ខេបអត្ថបទ ដោយបង្រួមវាទៅជាពាក្យ ឬរៀបចំពាក្យជាក់លាក់នៅក្នុងបរិបទរៀងៗខ្លួន។

## 4.12. លទ្ធផលរំពឹងទុក

អ្នកស្រាវជ្រាវគួរតែរួមបញ្ចូលលទ្ធផលសិក្សាដែលរំពឹងទុក។ ផ្តល់លទ្ធផលរកឃើញវិជ្ជមាន និងអវិជ្ជមានអំពីគុណសម្បត្តិវិទ្យាសាស្ត្រស្មើគ្នា នៅក្នុងលទ្ធផលរកឃើញដែលរំពឹងទុក។ លើសពីនេះ អ្នកស្រាវជ្រាវគួរតែផ្តល់សេចក្តីថ្លែងការណ៍អំពីសារៈសំខាន់ដែលបង្ហាញពីផលប៉ះពាល់ចំពោះការអនុវត្តគ្លីនិក (clinical practice) ឬគោលនយោបាយសុខភាព ជៀសវាងការស្មាន និងការគិតហួសប្រមាណ (overgeneralization)។ លើសពីនេះ សេចក្តីថ្លែងការណ៍ដែលពាក់ព័ន្ធអាចបង្ហាញថាតើការស្រាវជ្រាវបន្ថែមប្រហែលជាចាំបាច់ឬអត់ មុនពេលដែលព័ត៌មានអាចត្រូវបានអនុវត្តនៅក្នុងផ្នែកសុខភាព។

## 4.13. ក្រមសីលធម៌ស្រាវជ្រាវ

ព័ត៌មានលម្អិតស្តីពីការអនុម័តក្រមសីលធម៌ (ឬសេចក្តីថ្លែងការណ៍អំពីមូលហេតុដែលវាមិនចាំបាច់) គួរតែត្រូវបានផ្តល់ជូននៅក្នុងផ្នែកនេះ។ ការសិក្សាទាំងអស់ដែលទាក់ទងនឹងបុគ្គលគោលដៅជាមនុស្ស គួរតែរួមបញ្ចូលព័ត៌មានលម្អិតនៃការយល់ព្រមក្នុងការសិក្សា។ អ្នកស្រាវជ្រាវគួរតែពណ៌នាអំពីជំហាននៃការការពាររបស់ពួកគេដើម្បីការពារបុគ្គលគោលដៅជាមនុស្ស ធានាការសម្ងាត់នៃអត្តសញ្ញាណផ្ទាល់ខ្លួន ធានាសុវត្ថិភាពទិន្នន័យ និងផ្តល់ឯកសារសម្រាប់ការយល់ព្រមចូលរួម។ ព័ត៌មានលម្អិតបន្ថែមនៅក្នុងក្រមសីលធម៌ស្រាវជ្រាវត្រូវបានពិនិត្យនៅក្នុងផ្នែកទី៥ ក្រមសីលធម៌ស្រាវជ្រាវ និងការត្រួតពិនិត្យ (Section 5. Research Ethics and Review.)។

## 4.14. ឯកសារយោង

ការដកស្រង់ និងគន្ថនិទ្ទេស (bibliographies) គឺជាសមាសធាតុសំខាន់នៃរាល់ឯកសារស្រាវជ្រាវ។ ការយោង (Referencing) គឺជាវិធីសាស្ត្រវិទ្យាសាស្ត្រមួយសម្រាប់កំណត់ប្រភពទិន្នន័យតាមរយៈការផ្តល់នូវសំណុំស្តង់ដារនៃព័ត៌មានដែលជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ លទ្ធភាពស្វែងរក (searchability) និងការទាញយកមកវិញ (retrieval)។ ទន្ទឹមនឹងនោះ ការយោងមានបញ្ចូលតែប្រភពព័ត៌មានដែលបានដកស្រង់នៅក្នុងឯកសារស្រាវជ្រាវ គន្ថនិទ្ទេស (bibliographies) ផ្តល់បញ្ជីនៃប្រភពពាក់ព័ន្ធទាំងអស់ ថាតើពួកគេត្រូវបានដកស្រង់ ឬក៏អត់។

ការដកស្រង់ក្នុងអត្ថបទ (In-text citations) ត្រូវបានប្រើដើម្បីធ្វើផ្ទៀតផ្ទាត់ការអះអាងរបស់អ្នកនិពន្ធ(authors' claims) និងបង្កើតទំនាក់ទំនងរវាងការសិក្សាជាច្រើន ដែលអនុញ្ញាតឱ្យអ្នកអានប្រៀបធៀប និងដឹងភាពផ្ទុយគ្នានឹងការរកឃើញរបស់ពួកគេ។ វិវេចនាសាស្ត្រផ្នែកវេជ្ជសាស្ត្រ (Medical literature) ភាគច្រើនអនុវត្តតាម Vancouver សមាគមចិត្តសាស្ត្រអាមេរិក (APA) និង Harvard styles ក្នុងចំណោមទម្រង់ការដកស្រង់អ្នកប្រាជ្ញជាច្រើន។ ទម្រង់កាលបរិច្ឆេទអ្នកនិពន្ធ (បែបបទ APA និង Harvard) ឬទម្រង់លេខ (ស្តាយ Vancouver) ត្រូវបានប្រើប្រាស់។

នៅពេលប្រើប្រាស់ទម្រង់សមស្រប (appropriate format) សម្ភារៈជាច្រើនដូចជា អត្ថបទទិនានុប្បវត្តិ សៀវភៅទាំងមូល ផ្នែកខ្លះនៃសៀវភៅ ដំណើរការសន្និសីទ (conference proceedings) និងឯកសារ និក្ខេបបទ និងសារណា ប៉ាតង់ អត្ថបទកាសែត ឯកសារច្បាប់ សំបុត្រ និងទំនាក់ទំនងផ្ទាល់ខ្លួនផ្សេងទៀត អត្ថបទដែលមិនបានបោះពុម្ព (unpublished manuscripts) អត្ថបទអេឡិចត្រូនិក សៀវភៅអេឡិចត្រូនិច កម្មវិធី (software) ប្លុក និងគេហទំព័រទាំងអស់ ត្រូវបានចាត់ទុកថាជាប្រភពត្រឹមត្រូវនៃឯកសារយោងដែលអាចដកស្រង់បាន (citable references)។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រាវជ្រាវត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវ និងភាពពេញលេញ នៃឯកសារយោងរបស់ខ្លួន និងសម្រាប់ការដកស្រង់អត្ថបទត្រឹមត្រូវ (correct text citation)។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ កម្មវិធីយោងតាមគេហទំព័រ (web-based referencing) និងមិនមែនគេហទំព័រ(non-web-based referencing) មួយចំនួនត្រូវបានបង្កើតឡើង។ ឧបករណ៍ទាំងនេះកំណត់អត្តសញ្ញាណ និងរក្សាទុករាល់ទិន្នន័យសមាសធាតុ (component data fields) នៃសេចក្តីយោង ដូច្នេះច្បាប់នៃទម្រង់ផ្សេងៗគ្នា អាចត្រូវបានអនុវត្តចំពោះសមាសធាតុនីមួយៗ ដោយអនុលោមទៅតាមស្តាយយោងផ្សេងៗគ្នា។ កំណត់ចំណាំនៅខាងចុង (EndNote) និង Thomson Reuters' Reference Manager គឺជាអត្ថបទពីរដែលបង្កើតឡើងច្រើនបំផុតស្តីពីកម្មវិធីយោង (reference software)។ កម្មវិធីយោងដែលមានមូលដ្ឋានលើផ្ទៃកុំព្យូទ័រ (desktop-based reference program) ទាំងនោះឃើញមានចំនួនប្រើប្រាស់ច្រើនបំផុត ដោយសារតែប្លង់របស់ពួកវាអាចកែប្រែបាន។ ពួកគេរក្សាទុកឯកសារយោង និងឯកសារពាក់ព័ន្ធទាំងអស់នៅក្នុងបណ្ណាល័យក្រៅបណ្តាញ (offline libraries) នៅលើកុំព្យូទ័រផ្ទាល់។ ការដាក់ឱ្យប្រើប្រាស់ឧបករណ៍យោងបានបណ្តាលឱ្យមានការថយចុះនៃចំនួនពលកម្មដោយដៃ និងភាពស្មុគស្មាញពាក់ព័ន្ធនឹងការគ្រប់គ្រងឯកសារយោង។

ស្តាយសំខាន់ៗមួយចំនួននៅក្នុងឯកសារយោងមានដូចខាងក្រោម៖

- លេខយោងតាមលំដាប់លំដោយដែលបង្ហាញក្នុងអត្ថបទ។
- កំណត់ឯកសារយោងនៅក្នុងអត្ថបទ តារាង និងចំណងជើងដែលមានលេខធំអារ៉ាប់
- នៅពេលរាយបញ្ជីឯកសារយោង សូមអនុវត្តតាមស្តាយ AMA style និងឈ្មោះសង្ខេបនៃទិនានុប្បវត្តិយោងទៅតាមបញ្ជីទិនានុប្បវត្តិនៅក្នុង PubMed ។

- រាយបញ្ជីអ្នកនិពន្ធ និង/ឬអ្នកកែសម្រួលរហូតដល់ ៦ ឈ្មោះ។ ប្រសិនបើអ្នកនិពន្ធច្រើនជាង ៦ នាក់ ចូររាយបញ្ជីអ្នកនិពន្ធបីនាក់ដំបូងដែលតាមដោយ "et al" ។
- ពេលខ្លះឯកសារយោងទិនានុប្បវត្តិ រួមបញ្ចូលលេខចេញផ្សាយនៅក្នុងវង់ក្រចកបន្ទាប់ពីលេខច្បាប់។
- ឯកសារយោងចំពោះអត្ថបទគួរតែបញ្ចូលឈ្មោះអ្នកនិពន្ធតាមដោយអក្សរកាត់នៃឈ្មោះរបស់ពួកគេ។ រាយបញ្ជីអ្នកនិពន្ធទាំងអស់នៅពេលមានចំនួនបី ឬតិចជាងនេះ៖

  Gordon JB, Bennett AM. Tuberculosis in reindeer. *Scand Rev Respir Dis*. 1978; 96 (Suppl): 217-219.
- ឯកសារយោងចំពោះអត្ថបទស្នាដៃ៖ (សៀវភៅ/ឯកលេខនា) គួរតែរួមបញ្ចូលឈ្មោះអ្នកនិពន្ធ ចំណងជើងនៃស្នាដៃ លេខ ISSN នៃការបោះពុម្ពផ្សាយ ឈ្មោះនិពន្ធនាយក ទីកន្លែង និងឆ្នាំបោះពុម្ពលេខនៃច្បាប់ (number of the volume) និងលេខទំព័រទីមួយ និងចុងក្រោយ៖

  McPhee SJ, Winker MA, Rabow MW, Pantilat SZ, Markowitz AJ, eds. *Care at the Close of Life: Evidence and Experience*. New York, NY: McGraw Hill Medical; 2011.
- សេចក្ដីយោងចំពោះជំពូកក្នុងសៀវភៅគួរបញ្ចូលឈ្មោះអ្នកនិពន្ធ ចំណងជើងនៃជំពូកជាមួយនឹងពាក្យ "ក្នុង" (in) មុនឯកសារយោងនៃស្នាដៃ៖

  Girling DJ. The chemotherapy of tuberculosis. In: Ratledge C, Stanford J, Grange JM, eds. Biology of the mycobacteria. London, UK: Academic Press, 1989: pp 285-323.
- ឯកសារយោងអេឡិចត្រូនិចគួរតែបានផ្ដល់ឱ្យតែនៅពេលដែលការដកស្រង់ដើមមិនមាន។ សូមផ្ដល់ព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន រួមទាំងអាសយដ្ឋាន html។

  Centers for Medicare & Medicaid Services. CMS proposals to implement certain disclosure provisions of the Affordable Care Act. http://www.cms.gov/apps/media/press/factsheet.asp?Counter=4221. Accessed January 30, 2012.
- ឯកសារយោងចំពោះអត្ថបទដែលមិនទាន់ត្រូវបានបោះពុម្ពផ្សាយ គួរតែដាក់ឈ្មោះទិនានុប្បវត្តិជា (កំពុងស្ថិតក្នុងរោងពុម្ព) (In Press)' ហើយបញ្ចូលអត្ថបទ DOI។

  Murray CJL. Maximizing antiretroviral therapy in developing countries: the dual challenge of efficiency and quality [In Press]. *JAMA*. doi:10.1001/jama.2014.16376
- ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន គួរតែត្រូវបានផ្ដល់ឱ្យនៅក្នុងអត្ថបទជាមួយនឹងឈ្មោះរបស់បុគ្គលដែលបានលើកឡើង និងដោយមានការយល់ព្រមពីគាត់។

## 4.15. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធនៅក្នុងពិធីការស្រាវជ្រាវអាចរួមបញ្ចូល៖ (1) CVs របស់ PI, Co-PIs និង អ្នកស្រាវជ្រាវ។ (2) កម្រងសំណួរ (អង់គ្លេស & ខ្មែរ) (3) ទម្រង់ការយល់ព្រម (ភាសាអង់គ្លេស & ខ្មែរ) និង (4) ឯកសារផ្សេងទៀត (ដូចជាលិខិតគាំទ្រ ប្រភពមូលនិធិ ទំនាស់ផលប្រយោជន៍)។

# 5. ក្រមសីលធម៌ស្រាវជ្រាវ និងការពិនិត្យឡើងវិញ

## 5.1. សារៈសំខាន់នៃក្រមសីលធម៌ស្រាវជ្រាវ

ការប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ក្នុងការស្រាវជ្រាវជំងឺរបេង គឺចាំបាច់សម្រាប់អ្នកស្រាវជ្រាវ។ បទដ្ឋានសីលធម៌បានលើកកម្ពស់គោលបំណងនៃការស្រាវជ្រាវ ដូចជាចំណេះដឹង និងការជៀសវាងកំហុស។ ឧទាហរណ៍ ការហាមឃាត់ប្រឆាំងនឹងការប្រឌិត ការក្លែងបន្លំ ឬការបំភាន់ទិន្នន័យស្រាវជ្រាវ លើកកម្ពស់ភស្តុតាងបែបវិទ្យាសាស្ត្រ និងកាត់បន្ថយកំហុស។ ដូច្នេះហើយ គោលនយោបាយស្តីពីការប្រព្រឹត្តខុសក្នុងការស្រាវជ្រាវ ទំនាស់ផលប្រយោជន៍ ការការពារមនុស្ស និងការថែទាំ និងការប្រើប្រាស់សត្វ គឺចាំបាច់ដើម្បីធ្វើឱ្យប្រាកដថា អ្នកស្រាវជ្រាវអាចទទួលខុសត្រូវចំពោះសាធារណជន។ បទដ្ឋានសីលធម៌ក្នុងការស្រាវជ្រាវ ក៏ជួយកសាងការគាំទ្រសាធារណៈសម្រាប់ការស្រាវជ្រាវផងដែរ។ មនុស្សទំនងជាផ្តល់មូលនិធិដល់គម្រោងស្រាវជ្រាវ ប្រសិនបើពួកគេអាចជឿជាក់លើគុណភាព និងសុចរិតភាពនៃការស្រាវជ្រាវ។

ដោយសារការស្រាវជ្រាវជារឿយៗពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលយ៉ាងយកចិត្តទុកដាក់ក្នុងចំណោមវិស័យ (disciplines) និងស្ថាប័នផ្សេងៗគ្នា បទដ្ឋានសីលធម៌បានលើកកម្ពស់តម្លៃដែលមានសារៈសំខាន់សម្រាប់ការងារសហការ ដូចជាការជឿទុកចិត្ត ការទទួលខុសត្រូវ ការគោរព និងយុត្តិធម៌។ ដើម្បីការពារកម្មសិទ្ធិបញ្ញា និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ស្តង់ដារសីលធម៌មួយចំនួនក្នុងការស្រាវជ្រាវ (ដូចជាលក្ខណៈវិនិច្ឆ័យនៃភាពជាអ្នកនិពន្ធ បទប្បញ្ញត្តិស្តីពីការរក្សាសិទ្ធិ និងប៉ាតង់ គោលនយោបាយចែករំលែកទិន្នន័យ និងច្បាប់រក្សាការសម្ងាត់នៅក្នុងផ្នែកការពិនិត្យដោយអ្នកស្រាវជ្រាវផ្សេងទៀត (peer review) ត្រូវបានបង្កើតឡើង។ អ្នកស្រាវជ្រាវភាគច្រើនចង់ទទួលបានក្រេឌីតសម្រាប់ការរួមចំណែករបស់ពួកគេ ប៉ុន្តែមិនចង់ឱ្យគំនិតរបស់ពួកគេត្រូវបានលួច ឬបញ្ចេញឱ្យដឹងជាមុននោះទេ (disclosed prematurely)។

លើសពីនេះ បទដ្ឋានសីលធម៌ក្នុងការស្រាវជ្រាវអាចលើកកម្ពស់តម្លៃសីលធម៌ និងសង្គមសំខាន់ៗមួយចំនួន ដូចជាទំនួលខុសត្រូវសង្គម សិទ្ធិមនុស្ស សុខុមាលភាពសត្វ ការអនុលោមតាមច្បាប់ និងសុខភាពសាធារណៈ និងសុវត្ថិភាព។ ជម្លោះខាងសីលធម៌ក្នុងការស្រាវជ្រាវអាចប៉ះពាល់ដល់មនុស្ស និងសត្វ អ្នកស្រាវជ្រាវ និងសាធារណៈជនយ៉ាងខ្លាំង។

## 5.2. ការការពារបុគ្គលគោលដៅជាមនុស្ស

នៅពេលធ្វើការស្រាវជ្រាវលើបុគ្គលគោលដៅជាមនុស្ស អ្នកស្រាវជ្រាវគួរតែចាប់អារម្មណ៍ទៅលើ៖

- កាត់បន្ថយគ្រោះថ្នាក់ និងហានិភ័យ និងផ្តល់អត្ថប្រយោជន៍ជាអតិបរមា។
- គោរពសេចក្តីថ្លៃថ្នូរបស់មនុស្ស ឯកជនភាព និងស្វ័យភាព។

- មានការប្រុងប្រយ័ត្នពិសេសជាមួយក្រុមមនុស្សដែលងាយរងគ្រោះ។
- ចែកចាយអត្ថប្រយោជន៍ និងបន្ទុកនៃការស្រាវជ្រាវដោយស្មើភាព និង
